# ការសរសើរ និងការថ្វាយបង្គំ



**លោកដុកទ័រ អេ អែល ហ្គីល** គឺជាកំពូលអ្នកនិពន្ធសៀវភៅជិត២០លានក្បាល ដែលបានបោះពុម្ពហើយ ។ ការងារជាសាវ៉កផ្នែកអន្តរជាតិរបស់គាត់នេះ គឺបានចាប់យកមនុស្សជាង៨០ជនជាតិ ។ គាត់បានអធិប្បាយទៅដល់ហ្វូងមនុស្សជាងម្ភៃម៉ឺននាក់ ដោយមានការបញ្ជាក់មកពីព្រះ និងព្រះបន្ទូលរបស់ព្រះអង្គ ជាមួយនឹងទីសម្គាល់នៃការប្រោសឱ្យជា និងការអស្ចារ្យផ្សេងៗ ។ ការអនុវត្តន៏ដែលមានពេញដោយអំណាចចេស្តារបស់គាត់ សេចក្តីបង្រៀនដែលមានពេញដោយជីវិតផ្លាស់ប្រែ និងដែលមានលទ្ធភាព នោះគឺតាមរយៈវីឌីអូ អូឌីយ៉ូ និងសៀវភៅជាច្រើនភាសា នោះសូមមើលទៅក្នុងវិបសាយ:www.gillministries.com


*១. គំរូរបស់ព្រះសម្រាប់ការសរសើរ និងការថ្វាយបង្គំ. ១៤៩*

*២. ហេតុអ្វី អ្នកណា ពេលណា ហើយនៅកន្លែងណា... ១៦១*

*៣. គោលបំណងដ៏អស់កល្បរបស់ព្រះ .................... ១៦៩*

*៤. ការចង្អុលបង្ហាញពីការសរសើរ និងការថ្វាយបង្គំ... ១៧៥*

*៥. ជ័យជម្នះតាមរយៈការសរសើរនិងការថ្វាយបង្គំ.... ១៨៣*


# ការសរសើរ និងការថ្វាយបង្គំ

## *មេរៀនទី ១: គំរូរបស់ព្រះសម្រាប់ការសរសើរ និងការថ្វាយបង្គំ*

### I. រោងឧបោសថ និងព្រះវិហារ

### ក. រោងឧបោសថរបស់លោកម៉ូសេ

រោងឧបោសថរបស់លោកម៉ូសេ គឺមានទ្វារដែលអនុញ្ញាតឱ្យចូលបានទៅក្នុងទីធ្លា ។ ពួកអ្នកជឿទាំងអស់អាចចូលបានតែទៅក្នុទីធ្លានោះឯង ។ រីឯពួកសង្ឃគឺត្រូវបានចូលទៅជាប្រចាំថ្ងៃ តាមរយៈទីធ្លាទៅក្នុងទីបរិសុទ្ធ សម្រាប់បំពេញការងាររបស់ពួកគេទៅឯពួកបណ្តាជន និងទៅឯព្រះ ។ ក្នុងមួយឆ្នាំម្តង គឺសម្តេចសង្ឃត្រូវចូលទៅក្នុងទីបរិសុទ្ធបំផុត ដែលមានហឹបនៃសេចក្តីសញ្ញានៅទីនោះ ។

**១. ភាពជាសង្ឃ**

លោកអើរ៉ុនដ៏ជាសង្ឃៈ កូនចៅរបស់លោកអើរ៉ុនបានចូលទៅក្នុងរោងឧបោសថ របស់លោកម៉ូសេជាប្រចាំថ្ងៃ ក្រោយមកទៀតក៏ចូលទៅក្នុងព្រះវិហាររបស់ស្តេចសាឡូម៉ូន នៅសម័យសព្វថ្ងៃនេះ យើងជាអ្នកជឿគឺជាសង្ឃ យើងត្រូវតែចូលមកជារៀងរាល់ថ្ងៃ ទៅក្នុងព្រះវត្តមានរបស់ទ្រង់ដែរ ។

**២. ទីបរិសុទ្ធបំផុត**

ទីបរិសុទ្ធបំផុតទាំងនៅផែនដី និងនៅលើបល្ល័ង្ករបស់ព្រះ ក្នុងនគរស្ថានសួគ៌ គឺមានឋានៈស្មើៗគ្នា ។ ហឹប ដែលបានគ្របបាំងលើទីសន្តោសប្រោស គឺជាតួយ៉ាងនៃបល្ល័ង្ករបស់ព្រះ ។ ការចូលទៅឯទីបរិសុទ្ធបំផុត គឺជាការចូលទៅក្នុងព្រះវត្តមានរបស់ព្រះ ។

ក្នុងពេលមួយរំពេចភ្លាម១ ដែលព្រះយេស៊ូវទ្រង់បានសុគតនៅលើឈើឆ្កាង នោះវាំងននដែលនៅក្នុងព្រះវិហារ ដែលជាតំណាងឱ្យការញែកមនុស្សចេញពីព្រះ ក៏រហែកជាអធិធម្មជាតិដាច់ចេញពីគ្នា ចាប់តាំងពីលើចុះមកដល់ក្រោម ។ មនុស្សមិនត្រូវការញែកចេញពីព្រះដោយព្រោះអំពើបាបតទៅទៀតឡើយ ។ អំពើបាបរបស់មនុស្ស គឺអាចត្រូវបានទទួលការអត់ទោសឱ្យហើយ ។ ឥឡូវនេះមនុស្សប្រុសស្រីអាចចូលទៅក្នុងព្រះវត្តមានរបស់ព្រះ ដោយសេចក្តីក្លាហាន ។

## ខ. ការជឿនលឿននៃការសរសើរនិងការថ្វាយបង្គំ

សូម្បីតែមានការជឿនលឿននៃការចូលមក តាមរយៈពួកសង្ឃនៅក្នុងគ្រាសញ្ញាចាស់ក៏ដោយ ក៏មានការជឿនលឿនក្នុងការចូលមកនៅសម័យសព្វថ្ងៃនេះដែរ គឺយើងជាពួកសង្ឃជាអ្នកជឿ ក៏ត្រូវចូលមកជាប្រចាំថ្ងៃចំពោះព្រះវត្តមានរបស់ទ្រង់ ក្នុងការសរសើរនិងការថ្វាយបង្គំនេះដែរ ។ យើងត្រូវតែចូលមកជាប្រចាំថ្ងៃ ក្នុងពេលដែលយើងសរសើរថ្វាយបង្គំ និងអធិស្ឋានជាលក្ខណៈបុគ្គលផ្ទាល់ខ្លួនផងដែរ ។ យើងត្រូវតែចូលមករួមគ្នា ជារូបកាយទាំងមូលគឺនៅពេលនៃការរួមប្រជុំគ្នាម្តង១នោះ ។ ការចូលមកនេះ គឺតម្រូវឱ្យមានសកម្មភាពក្នុងការស្តាប់បង្គាប់ គឺជាផ្នែករបស់យើង ។ ព្រះទ្រង់សព្វព្រះហឫទ័យឱ្យយើងចូលមក ឯព្រះវត្តមានព្រះអង្គ ប៉ុន្តែ យើងត្រូវតែចាប់យកនូវភាពស្និទ្ធស្នាល ក្នុងការធ្វើយ៉ាងដូច្នោះដែរ ។

### ១. សេចក្តីបង្រៀនរបស់ស្តេចដាវីឌ

ព្រះគម្ពីរទំនុកដំកើង ១០០:៤

យើងចូលតាមទ្វារព្រះអង្គ ដោយអរព្រះគុណ ។ យើងមិនអាចចូលមកឯព្រះអង្គ ដោយរមិលគុណនៅក្នុងចិត្តនោះទេ ។ ចម្រៀងទីមួយរបស់យើង គឺដែលយើងបានចូលមកក្នុងការសរសើរ គឺត្រូវតែចង្អុលបង្ហាញពីការបាក់ទឹកចិត្តរបស់យើង ដោយការអរព្រះគុណដល់ព្រះអម្ចាស់នោះឯង ។

### ២. ទីលាននៃការសរសើរ

ពេលដែលយើងចូលមកតាមទ្វារ នោះយើងបាននៅក្នុងទីលាន ។ ត្រូវតែមានការជឿនលឿន ក្នុងការចូលឯព្រះវត្តមានរបស់ព្រះអង្គ ។ យើងមិនត្រូវត្រៀមខ្លួន ចូលមកក្នុងទីបរិសុទ្ធបំផុត ដែលនៅក្នុងពេលដ៏ជិតស្និទ្ធបំផុតនៃការថ្វាយបង្គំ ដែលមានភាពភ័យខ្លាចនោះទេ លុះត្រាតែយើងបានបញ្ជូនមក ជាពេលវេលាដំបូងនៅទីលាននោះតែប៉ុណ្ណោះ ។ នៅក្នុងទីលាន យើងបានទទួលនូវការបង្រៀនក្នុងការចូលទៅតាមគ្រប់ការទាំងអស់ ដែលចង្អុលបង្ហាញពីការសរសើរតាមព្រះគម្ពីរ ។ នេះគឺជាការច្រៀង ការស្រែក ការទះដៃ ការលោតសរសើរ ដោយដៃរបស់យើង ដែលមានពេញដោយសេចក្តីអំណរ ហើយមានពេលវេលាជាញឹកញាប់ ក្នុងការរាំនៅចំពោះព្រះអម្ចាស់ គឺពេលដែលយើងបញ្ជាក់ពីការសរសើររបស់យើងនោះឯង ។

ពេលដែលយើងចូលទៅដល់ទីលាន នៃការសរសើរនោះ យើងក៏ចាប់ផ្តើមទទួលអារម្មណ៍ថា បានចូលមកខាងវិញ្ញាណរបស់យើង កាន់តែជិត

ស្និទ្ធនឹងព្រះ ។ យើងត្រូវចូលមកដោយយឺត១ ដោយបានទទួលជោគជ័យ តាមការដែលទ្រង់សព្វព្រះហឫទ័យ ។

### ៣. ទីបរិសុទ្ធ

យើងចាប់ផ្តើមចូលមកកាន់តែខ្ពស់ឡើង ក្នុងការសរសើរ គឺយើងបានចូលមកឯទីបរិសុទ្ធ ក្នុងការថ្វាយបង្គំនោះឯង ។

### ៤. ទីបរិសុទ្ធបំផុត

ក្នុងមួយរំពេចនោះ យើងមិនមែនរាំ ឬទះដៃរបស់យើងតែរហូតនោះទេ ។ យើងរឹតតែបានចូលក្នុងព្រះវត្តមានរបស់ព្រះ ដែលដៃរបស់បានចាប់ផ្តើមលើកឡើង ចុះចូលទៅឯព្រះអង្គ ក្នុងការគោរពកោតខ្លាច។ ក្រុមតន្ត្រីក៏ចាប់ផ្តើមបន្ថយល្បឿន ។ តើជាបន្តបន្ទាប់ក្នុងមួយរំពេចនោះ យើងត្រូវធ្វើដូចម្តេច មុនពេលយើងត្រូវបញ្ឈប់ ។ ភាពបរិសុទ្ធនៃព្រះវត្តមានរបស់ព្រះ គឺស្ទើរតែមានច្រើនកាន់តែលើសលុបឡើងហើយ ។

ពេលដែលយើងបន្តចូលក្នុងព្រះវត្តមាន នោះក៏មានទឹកភ្នែកហូរចុះមកលើផែនថ្កាល់ហើយដែរ ។ ជួនកាលគ្រប់ទាំងអស់ដែលយើងអាចធ្វើបាន គឺឈប់លេងភ្លេង និងឈប់ច្រៀង និងចាប់ផ្តើមទៅជាស្ងប់ស្ងាត់ នៅក្នុងព្រះវត្តមាននៃព្រះវិញ្ញាណបរិសុទ្ធ ។ យើងក៏មានការមិនដឹងខ្លួន ពីអ្នកដែលនៅជុំវិញយើង ។ គឺយើងដឹងតែពីព្រះតែមួយអង្គប៉ុណ្ណោះ ។ យើងកំពុងតែឈរនៅក្នុងព្រះវត្តមានរបស់ទ្រង់ គឺបានវង្វេង នៅក្នុងសេចក្តីស្រឡាញ់របស់ទ្រង់តែប៉ុណ្ណោះ ។ ស្ទើរតែគ្មានលំនឹងនៅក្នុងខ្លួន គឺធ្វើឱ្យយើងបានដួលចុះ សូម្បីតែសម្តេចសង្ឃក៏បានចូលទៅក្នុងវាំងននផងដែរ ។ យើងកំពុងតែឈរនៅក្នុងទីបរិសុទ្ធបំផុត ហើយយើងក៏កាន់តែមានការជិតស្និទ្ធ ស្និទ្ធស្នាល ទៅក្នុងព្រះវត្តមានរបស់ព្រះ ។ ការចាក់ប្រេង និងអំណាចចេស្តាក៏បានប្រាកដឡើង ។ មានមនុស្សជាច្រើននឹងបានក្រាបចុះ ឬក៏បានឱនលំទោនដោយខ្លួនឯង នៅចំពោះទ្រង់ ។ មានអ្នកខ្លះទៀតក៏អាចបាន ទៅជាមួយនឹងព្រះវិញ្ញាណ ។

## គ. រោងឧបោសថរបស់ស្តេចដាវីឌ

គឺជាស្តេចដាវីឌដែលបាននាំមកនូវហឹប ត្រឡប់មកកាន់ក្រុងយេរូសាឡិមវិញ បន្ទាប់ពីបានទទួលនូវការរឹបអូសយកទៅ ។ ស្តេចដាវីឌគឺជាបុរសម្នាក់ ដែលមានចិត្តទោរទៅរកព្រះ ហើយជាអ្នកដែលនៅតែបន្តការច្រៀង នៅក្នុងព្រះវត្តមានរបស់ព្រះអង្គ ។ អស់រយៈកាល៤០ឆ្នាំ រហូតដល់ព្រះវិហាររបស់ស្តេចសាឡូម៉ូនត្រូវបានសង់ហើយ រីឯហឹប គឺជាតំណាងឱ្យព្រះវត្តមានរបស់ព្រះ ដែលទ្រង់បានគង់នៅក្នុងរោងឧបោសថរបស់ស្តេចដាវីឌ ។ គឺគ្មានវាំងននដែលញែកចេញពីមនុស្ស និងព្រះទេ ។ ហឹបគឺជាការរំឭកដ៏ពេញលេញពីពួកអ្នកថ្វាយបង្គំទាំងអស់ ។ មានតែយញ្ញបូជាដែលនៅក្នុងរោងឧបោសថរបស់ស្តេចដាវីឌទេ ដែលនៅតែបន្តថ្វាយយញ្ញបូជានៃការសរសើរដល់ព្រះនោះ ។ រោងឧបោសថរបស់ស្តេចដាវីឌ បានត្រឡប់មកជាគំរូនៃការថ្វាយបង្គំសម្រាប់ពួកជំនុំនៅសម័យសព្វថ្ងៃនេះ ។

សម័យសព្វថ្ងៃនេះ យើងមានការពិសោធន៍ពីការសម្រេចតាមហោរារបស់ព្រះទាំងនេះ គឺព្រះទ្រង់កំពុងតែកែនូវការសរសើរ និងការថ្វាយបង្គំដ៏ពិតចំពោះពួកជំនុំរបស់ព្រះអង្គ ។ ដូចជាស្តេចដាវីឌបានបើកឱ្យយើងម្នាក់ៗសម្រេចចិត្ត ឱ្យមានខ្សែទឹករស់ នៅកំឡុងពេលនៃការធ្វើឱ្យស្រស់បស់ទាំងនេះ ។ ចូរយើងចូលទៅក្នុងព្រះវត្តមានរបស់ទ្រង់ និងការបញ្ចេញនូវវិញ្ញាណរបស់យើងឱ្យបានស្រស់បស់ឡើង ឱ្យថ្មីឡើង ហើយឱ្យបានចង្អុលបង្ហាញនូវការសរសើរដល់ព្រះ ដែលពេញដោយអំណាចចេស្តា ។

សេចក្តីអធិស្ឋានរបស់ខ្ញុំ គឺដែលលោកអ្នកនឹងបានចូលមកកាន់តែជិតព្រះ ហើយឱ្យកាន់តែជិតស្និទ្ធនឹងព្រះវត្តមានរបស់ព្រះ ព្រមទាំងមានបទពិសោធន៍ក្នុងភាពស្និទ្ធស្នាល និងមានជីវិតផ្លាស់ប្រែ គឺមានបទពិសោធន៍នៃការថ្វាយបង្គំដ៏ពិត ។

នៅក្នុងព្រះគម្ពីរកិច្ចការ ១៥:១៦-១៧ លោកយ៉ាកុបបានកត់ចេញមកពីព្រះគម្ពីរអេម៉ុស ៩:១១-១២ ។

## ឃ. ព្រះវិហាររបស់ស្តេចសាឡូម៉ូន

យើងមានការពណ៌នាពិរោះក្បោះក្បាយ ពីពេលវេលាជាបន្តបន្ទាប់ដែលនិយាយពីហឹបនៃសេចក្តីសញ្ញា ដែលបាននាំចូលទៅក្នុងព្រះវិហាររបស់ស្តេចសាឡូម៉ូន ។

ព្រះគម្ពីរ ១ពង្សាវតារក្សត្រ ៨:១០-១១

## ង. ការប្រណាំងប្រជែងរបស់យើង

នៅសម័យសព្វថ្ងៃនេះ ពួកអ្នកជឿដ៏តិចតួចបំផុតដែលមានការពិសោធន៍ពីការនេះ ។ យើងគួរតែរៀបចំចិត្តរបស់យើង ។ យើងចូលទៅតាមសេចក្តីបង្រៀន និងតាមគំរូរបស់ព្រះអង្គ ។ យើងបញ្ចេញនូវវិញ្ញាណរបស់យើង ព្រលឹងរបស់យើង និងរូបកាយរបស់យើង ឱ្យចូលទៅក្នុងភាពមានសេរី និងការចង្អុលបង្ហាញជាបន្ត នូវការសរសើរដែលគ្មានកម្រិត គឺនៅពេលដែលយើងបានចូលទៅដល់ទីលាន ។ យើងត្រូវបន្តចូលឱ្យបានកាន់តែជិតព្រះ ។ ទ្រង់បានសម្រេចព្រះទ័យ ឱ្យមានភាពស្និទ្ធស្នាលជាមួយនឹងកូនក្រមុំរបស់ទ្រង់ ។ ទោះជាយ៉ាងណាក៏ដោយ យើងត្រូវតែច្របាច់បញ្ចូលឱ្យបានកាន់តែជិតស្និទ្ធឡើងៗ រហូតដល់ពេលយើងបានមកជាតែមួយជាមួយនឹងព្រះអង្គ ។ ឱតើព្រះទ័យព្រះអង្គនៅក្នុងពេលភ្លាមៗនេះនឹងច្របាច់ចូលកាន់ជិតឡើង ដោយរបៀបណាទៅ ។ ចិត្តរបស់យើងគឺត្រូវតែបានជ្រើសតាំង ចុះចូល និងបន្តនូវភាពដ៏មានតម្លៃដ៏យូរអង្វែង ឱ្យមានភាពបរិសុទ្ធ ដែលមិនអាចនឹងពណ៌នាបាននៅពេលភ្លាមៗនេះ ចំពោះការថ្វាយបង្គំដ៏ពិត ។

ម្យ៉ាងទៀត យើងបានចូលមកខាងក្នុងហើយ យើងមិនត្រូវថយចេញពីព្រះវត្តមានរបស់ព្រះអង្គឡើយ ។ យើងត្រូវតែតាំងនៅ និងចូលស៊ុបនៅ ។ ពេលដែលយើងធ្វើការនេះ ជីវិតរបស់យើងនឹងមានការផ្លាស់ប្រែ ។ យើងនឹងនៅតែចូលឱ្យកាន់តែជិតដែលជាការផ្ចិតមិនអាចលុបជ្រះបាន ចំពោះព្រះបុគ្គលិកលក្ខណៈរបស់ព្រះអង្គ គឺបានធ្វើវិញ្ញាណរបស់យើងកាន់តែឡើងខ្ពស់ទៅៗ ។ យើងចំណាយពេលកាន់តែច្រើននៅក្នុងព្រះវត្តមានរបស់ទ្រង់ទាំងស្រុង គឺឱ្យបានស្និទ្ធស្នាលនឹងព្រះអង្គ នោះវិញ្ញាណរបស់យើងក៏បានអនុលោមទៅតាមរូបភាពរបស់ព្រះអង្គ នៅក្នុងជីវិតរបស់យើង ក៏នឹងមានការផ្លាស់ប្រែចូលទៅក្នុងរូបកាយ នៃព្រះរាជបុត្រារបស់ព្រះអង្គព្រះនាមព្រះយេស៊ូវ ហើយយើងនឹងបានត្រឡប់មកជាដូចនឹងព្រះអង្គ កាន់តែច្រើនឡើងប៉ុណ្ណោះដែរ ។

នេះគឺជាការទំនាក់ទំនង ដែលមានកម្រិតដ៏ខ្ពស់បំផុតនោះឯង ។ វាគឺជាការដែលយើងអាចស្តាប់ឮមកពីទ្រង់កាន់តែច្បាស់ឡើង ។ ចិត្តរបស់យើងបានស្រែកច្រៀង នោះគួរតែបានព្រមព្រៀងជាមួយនឹងស្តេចដាវីឌ ពេលដែលទ្រង់បានសរសេរទុកមក ។ ព្រះគម្ពីរទំនុកដំកើង ៤២:១-២ ។

## ការសម្រេចនៅសម័យសព្វថ្ងៃនេះ

គឺជាការមានសម្រស់ស្រស់ត្រកាល ព្រះវិញ្ញាណបរិសុទ្ធទ្រង់បានបំពេញថ្មីៗថែមមកទៀត និងបន្ថែមឱ្យមានបទពិសោធន៍នៅជុំវិញពភពលោកនេះ ។ ការងារថ្វាយបង្គំនៅក្នុងជំនុំជាច្រើន គឺមានការស្ងួតសោះកក្រោះនិងមានការសោកសង្រេង ។ ចម្រៀងចាស់ៗជួយបានត្រឹមតែពាក់កណ្តាល គឺដោយសារតែច្រៀងបទទំនុកតម្កើងចាស់ៗពេក ។ នៅសម័យសព្វថ្ងៃនេះ គឺរឹតតែធម្មតាទៅទៀតដែលគេបានរកឃើញពួកអ្នកជឿនៅក្នុងជំនុំដែលបានឈរនៅ ការច្រៀង ការទះដៃរបស់ពួកគេ ហើយសូម្បីតែការរាំសរសើរនៅចំពោះព្រះអម្ចាស់ ។ មានមនុស្សជាច្រើនដែលមានការពិសោធន៍ពីការថ្វាយបង្គំដ៏ពិត គឺនៅពេលដែលពួកគេលុតជង្គង់ចុះ ដោយលើកដៃឡើងថ្វាយទៅព្រះ ដែលមានពេញដោយទឹកភ្នែកស្រក់ចុះមកលើផ្ទៃមុខរបស់ពួកគេ គឺគេបានវង្វេងចូលទៅក្នុងព្រះវត្តមានរបស់ព្រះ នៅពេលដែលពួកគេបានច្រៀងនូវបទចម្រៀងថ្វាយបង្គំដល់ទ្រង់នោះ ។

ឧបករណ៍ភ្លេងគ្រប់ប្រភេទទាំងអស់ គឺត្រូវបានវិលត្រឡប់ចូលមកឯពួកជំនុំវិញហើយ ។ ក្រុមអ្នកច្រៀង ឬអ្នកចម្រៀង ដែលមានការប្រកបដ៏តិចតួចជាមួយនឹងព្រះ ក៏លែងនៅគង់វង់ក្នុងព្រះវិហារតទៅទៀតដែរ ។ ជំនួសឱ្យនូវការនេះពួកអ្នកជឿដែលមានការពិសោធន៍ និងមានការចាក់ប្រេងតាំងមកពីព្រះ ក៏មានការស្រស់ស្រាយ មានផ្លូវថ្មី ។

ជានិច្ចកាល សិរីល្អរបស់ផងព្រះក៏បានបំពេញដល់សាលប្រជុំ គឺអំណាចចេស្តារបស់ទ្រង់ បានបក់បោកចូលមកឆ្លងកាត់ព្រះវិហារ ដែលមានជារលកបក់បោកមកលើព្រះវិហារនោះ ។ នៅថ្ងៃនៃការឆ្លងព្រះវិហារ គឺគ្មានលទ្ធភាពនឹងឈរនៅបានឡើយ ពីព្រោះពពកនៃសិរីល្អរបស់ព្រះបានមកហ៊ុំជុំជិត ។

ព្រះគម្ពីរ ១ពង្សាវតារក្សត្រ ៨:១០-១១

## ច. ការតាំងពិពណ៌របស់ស្តេចដាវីឌ

ស្តេចដាវីឌគឺជាមនុស្សម្នាក់ ដែលដឹងពីរបៀបផ្តល់ឱ្យនូវការសរសើរដល់ព្រះ ។ សូមឱ្យពាក្យតាំងពិពណ៌របស់ទ្រង់បានចូលមកជិតយើង គឺមកចំកណ្តាលអ្វីដែលព្រះវិញ្ញាណបរិសុទ្ធទ្រង់កំពុងតែបានធ្វើសព្វថ្ងៃនេះ ក្នុងការកែជាថ្មីឡើងវិញ នៃការថ្វាយបង្គំដ៏ពិត ដល់ពួកជំនុំរបស់ទ្រង់ ។

ព្រះគម្ពីរទំនុកដំកើង ១៥០:១-៦

យើងគួរគប្បីសរសើរដល់ព្រះអម្ចាស់!

## II. ការសរសើរ និងការថ្វាយបង្គំ

### ក. និយមន័យ

#### ១. ការសរសើរ

ការសរសើរគឺជាការចង្អុលបង្ហាញ ពីដួងចិត្ត ការដឹងគុណ និងការអរព្រះគុណដល់ព្រះសម្រាប់គ្រប់ការទាំងអស់ ដែលទ្រង់បានធ្វើសម្រាប់យើង ។ វាគឺជាការចង្អុលបង្ហាញពីរូបកាយ និងពីការបញ្ចេញសម្លេងពីការអបអរ ដែលស្មោះត្រង់ចំពោះព្រះ

សម្រាប់គ្រប់ទាំងព្រះពរដ៏អស្ចារ្យ ដែលទ្រង់បានប្រទានពរមកនោះឯង ។

**២.ការថ្វាយបង្គំ**

ការថ្វាយបង្គំគឺជាការដ៏ខ្ពស់បំផុត បន្ទាប់ពីការសរសើរ ។ គឺជាការទៅជាលំដាប់លំដោយ ដែលមានការគិត ពីព្រះពរដ៏អស្ចារ្យទាំងអស់របស់ទ្រង់មកដល់យើង គឺយើងត្រូវចង្អុលបង្ហាញពីការកោតសរសើរ និងការលើកតម្កើងរបស់យើងដល់ព្រះអង្គទ្រង់ សម្រាប់បុគ្គលភាព បុគ្គលិកលក្ខណៈ ការកំណត់ និងភាពគ្រប់លក្ខណ៍របស់ព្រះអង្គ ។

យើងកំពុងតែបំពេញការងារ ថ្វាយដល់ព្រះសម្រាប់អស់ អ្នកណាដែលទ្រង់បានដៅ និងមិនត្រឹមតែការអ្វីដែលទ្រង់មិនទាន់បានធ្វើសម្រាប់យើងនោះផងដែរ ។

**ខ. ការប្រៀបធៀបពីការសរសើរនិងការថ្វាយបង្គំ**

**១. របៀបនៃការសរសើរដែលត្រូវបានចង្អុលបង្ហាញ**

ក. និយាយបានត្រឹមត្រូវល្អអំពី

ខ. បញ្ជាក់ពីការកោតសរសើរសម្រាប់

គ. ពាក្យសរសើរ

ឃ. ការកំណត់

ង. ការថ្លែងសរសើរ

ច. ការទះដៃសាទរ

ឆ. សរសើរដោយការថ្លែងសំកថា

ជ. ការសរសើរពីសេចក្តីល្អ

ឈ. ការសរសើរគឺជាការនិយាយ ឬច្រៀងអំពីព្រះទ្រង់អស្ចារ្យយ៉ាងណាហ្ន៎ ទ្រង់បានធ្វើសម្រាប់យើង ច្រើនអ្វីម្ល៉េះហ្ន៎!

**២. របៀបនៃការថ្វាយបង្គំដែលត្រូវបានចង្អុលបង្ហាញ**

ក. បង្ហាញពីការយកចិត្តទុកដាក់

ខ. មានវិញ្ញាណនៃការភ្ញាក់រឭក

គ. ក្រាបចុះនៅចំពោះកម្មបទនៃការថ្វាយបង្គំ

ឃ. ការគោរពដែលមានតម្លៃចំពោះ

ង. ថ្វាយកន្លែងដល់

ច. ការថ្វាយបង្គំគឺជាការចរចា ឬការច្រៀងថ្វាយដល់ព្រះ ។ លោកអ្នកបានរំលងពីចំណុចនៃការគិតអំពីរឿងរ៉ាវដែលទ្រង់បានធ្វើរួចហើយ និងបានចូលមកថ្វាយបង្គំព្រះអង្គ សម្រាប់អស់អ្នកដែលទ្រង់គង់នៅជាមួយ ។

**៣. ការថ្វាយបង្គំគឺជាទម្រង់ដ៏ខ្ពស់បំផុតកៃការសរសើរ ។**

ក. ទីមួយ វាគឺជាអាកប្បកិរិយានៃចិត្ត ។

ខ. ការកាន់កាប់ដែលមានការគោរពខ្លាំង ជាមួយនឹងអ្នកបង្កើត

គ. ការចាប់ផ្តើមនូវការជញ្ជឹងគិតផ្នែកខាងក្នុងចិត្ត

ឃ. ការជញ្ជឹងគិតដ៏មានជម្រៅជ្រៅ ទៅលើភាពធំឧត្តម និងភាពមានតម្លៃរបស់ព្រះ ។

ង. បន្ទាប់មក វាគឺជាការបង្ហូរដែលធ្វើទៅដោយឯកឯង ចំពោះគំនិត និងអារម្មណ៍ទាំងនេះ ។ ការថ្វាយបង្គំមិនអាច "ត្រូវបានធ្វើការ" វាត្រូវតែបានចូលមកដោយនូវព្រះវិញ្ញាណ ។

ច. នៅទីបំផុត វាគឺជាការបង្ហូរចេញ នូវព្រលឹងក្នុងការចង្អុលបង្ហាញពីការចុះចូល ពីសតិស្មារតី ពីការអស្ចារ្យ និងពីការបូជា ដ៏មានជម្រៅជ្រៅ ។

## គ. តើអ្វីទៅគឺជាការថ្វាយបង្គំ?

មុនពេលដែលយើងអាចចូលទៅ ក្នុងការថ្វាយបង្គំ វាគឺជាការចាំបាច់ ក្នុងការយល់ដឹងពីការថ្វាយបង្គំគឺជាអ្វីនោះ ។

### ១. ដោយនូវព្រះវិញ្ញាណ

យើងអាចត្រឹមតែថ្វាយការថ្វាយបង្គំដ៏ពិត ទៅដល់ព្រះពីវិញ្ញាណរបស់យើង ។

ព្រះគម្ពីរយ៉ូហាន ៤:២៤

ចំពោះការថ្វាយបង្គំដោយវិញ្ញាណ គឺត្រូវតែថ្វាយបង្គំដោយអស់ពីចិត្តរបស់យើង ។ ចំពោះការថ្វាយបង្គំដោយវិញ្ញាណក៏មានន័យថា ការថ្វាយបង្គំអស់ពីវិញ្ញាណរបស់យើង ដោយនូវអំណាចចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ គ្រប់ទាំងអស់ដែលសំណាក់នៅក្នុងកន្លែងដូចគ្នា ដែលព្រះគម្ពីរហៅថាចិត្ត ឬវិញ្ញាណរបស់យើង ។

### ២. ដោយនូវសេចក្ដីពិត

ចំពោះការថ្វាយបង្គំដោយសេចក្ដីពិត គឺត្រូវតែថ្វាយបង្គំ និងបើកឱ្យព្រះអម្ចាស់ស្រាវជ្រាវរកជម្រៅចិត្តដ៏ជ្រៅផ្នែកខាងក្នុងរបស់យើង ។

ព្រះគម្ពីរសុភាសិត ២០:២៧

ព្រះគម្ពីរយ៉ូហាន ១៤:១៦-១៧

### ៣. ការសម្អាតខ្លួនយើង

ចាប់តាំងពីយើងមិនអាចថ្វាយបង្គំព្រះ ក្នុងផ្នែកខាងសាច់ឈាម វាគឺជាសំខាន់ដើម្បីសម្អាតខ្លួនយើងពីគ្រប់ទាំងគំនិតខាងសាច់ឈាម និងពីសេចក្ដីអាក្រក់ ដើម្បីឱ្យវិញ្ញាណរបស់យើងអាចថ្វាយបង្គំព្រះ ដោយព្រះវិញ្ញាណរបស់ទ្រង់ ។

ព្រះគម្ពីរកូល៉ុស ៣:៥

ព្រះគម្ពីរកូល៉ុស ៣:១៦-១៧

យើងត្រូវតែសម្អាតខ្លួនយើង ហើយថ្វាយបង្គំដល់ព្រះមកពីចិត្តដែលត្រូវចាក់ចេញ ។ សាច់ឈាមមិនអាចថ្វាយបង្គំព្រះបានទេ ។ ប្រសិនបើយើងកំចាត់ការទាំងអស់នោះដោយខ្លួនឯង នោះគឺមិនមែនមកពីព្រះទេ ហើយគ្មានអ្វីទុកនៅទេ គឺជាវិញ្ញាណរបស់យើងដែលថ្វាយបង្គំ ដោយព្រះវិញ្ញាណរបស់ព្រះ ។

## ឃ. លោកអ័ប្រាហាំគឺជាគំរូរបស់យើង

### ១. លោកអ័ប្រាហាំបានថ្វាយបង្គំ

ការយោងពីខគម្ពីរទីមួយ ចំពោះការថ្វាយបង្គំគឺជាការយកចិត្តទុកដាក់របស់លោកអ័ប្រាហាំ ។

ព្រះគម្ពីរលោកុប្បត្តិ ២២:៥-១៨

### ២. ក្រឹត្យវិន័យគឺជានិទ្ទេសទីមួយ

មានការគោលការណ៍នៃការបកស្រាយព្រះគម្ពីរមួយ គឺដែលត្រូវបានហៅថា "ក្រឹត្យវិន័យនិទ្ទេសទីមួយ" ។ វាបានសម្ដែងថា និទ្ទេសទីមួយនៃព្រះគម្ពីរ ចំពោះប្រធានបទ ដែលបានផ្ដល់មកឱ្យយើងនោះគឺជាការបញ្ជាក់យ៉ាងច្បាស់ ទៅលើអត្ថន័យ និងសេចក្ដីសំខាន់របស់វា នៅកន្លែងណាក៏ដោយ គឺតែងតែបានកើតឡើងនៅក្នុងព្រះគម្ពីរ ។

ការកើតឡើងទីមួយចំពោះពាក្យ "ថ្វាយបង្គំ" គឺត្រូវបានរកឃើញ នៅពេលដែលលោកអ័ប្រាហាំកំពុងតែបាននិយាយទៅកាន់មនុស្សកម្លោះៗ ដែលជូនដំណើរលោកអ៊ីសាក និងគាត់ ទៅកាន់ទីម៉ូរីយ៉ា ។

ការថ្វាយបង្គំ ឱ្យកាន់តែមានភាពធ្ងន់ធ្ងរទៅទៀត នោះគឺត្រូវបានបង្ហាឱ្យឃើញ ដោយការធ្វើនិទ្ទេសលើកទីមួយនេះឯង ។

## ៣. លោកអ័ប្រាហាំបានស្តាប់បង្គាប់

ការទទួលខុសត្រូវរបស់លោកអ័ប្រាហាំ ចំពោះព្រះរាជបញ្ជារបស់ព្រះ គឺជាការស្តាប់បង្គាប់មួយ ។

គ្មានផ្លូវណាសម្រាប់យើង ក្នុងស្រមើស្រមៃទៅលើការស្តាប់បង្គាប់អ្វីជាជាងការស្តាប់បង្គាប់ ចំពោះព្រះរាជបញ្ជានេះ គឺជាការទាមទាររបស់លោកអ័ប្រាហាំនោះឯង ។ លោកអ៊ីសាក គឺជាកូននៃសេចក្តីសន្យា ។

គាត់គឺត្រូវបានសម្រេចតាមសេចក្តីសញ្ញា ដែលព្រះទ្រង់បានធ្វើជាមួយនឹងលោកអ័ប្រាហាំ ។

## ៤. យញ្ញបូជាដ៏មានប្រពលភាព

សកម្មភាពនៃការថ្វាយបង្គំនៅពេលនោះ គឺជាសកម្មភាពដ៏ពិតប្រាកដនៃយញ្ញបូជា ដ៏មានប្រពលភាព ។ សកម្មភាពនៃការថ្វាយបង្គំនេះ គឺទាមទារពីលោកអ័ប្រាហាំនូវការដ៏ល្អបំផុតរបស់គាត់ គឺជាដង្វាយដ៏ខ្ពស់បំផុត ដែលគាត់អាចមានលទ្ធភាពនឹងធ្វើ ។

សកម្មភាពថ្វាយបង្គំ គឺនៅតែអាចបានជាដង្វាយជាលក្ខណៈបុគ្គលដ៏សំខាន់បំផុតនោះឯង ។

ការថ្វាយបង្គំដ៏ពិតមានន័យថា ការចុះចូលដ៏ពេញលេញ ទៅចំពោះព្រះហឫទ័យព្រះទាំងស្រុងនោះឯង ។ វាគឺជាការកំណត់នូវដង្វាយ ដ៏មានប្រពលភាពនោះឯង ។

## ៥. សកម្មភាពនៃការស្តាប់បង្គាប់ សេចក្តីជំនឿ

សកម្មភាពនៃការថ្វាយបង្គំ គឺជាសកម្មភាពនៃការស្តាប់បង្គាប់ និងសេចក្តីជំនឿ ។ លោកអ័ប្រាហាំមិនអាចធ្វើឱ្យមានការធ្លាក់ចុះ ក្នុងការថ្វាយបង្គំនោះឡើយ ។

នៅថ្ងៃទីបីនៃដំណើររបស់គាត់ ដើម្បីថ្វាយអ៊ីសាកនោះ លោកអ័ប្រាហាំបាននិយាយថា "យើងនឹងត្រឡប់ឯអ្នកវិញ" ។

សកម្មភាពនៃការស្តាប់បង្គាប់ បានវិលត្រឡប់មកកាន់សកម្មភាពនៃសេចក្តីជំនឿ ។

## ៦. ការចុះចូលដោយខ្លួនឯង

ការស្លាប់របស់លោកអ៊ីសាក គឺនឹងមានន័យពីសេចក្តីស្លាប់គ្រប់បែបយ៉ាង ដែលលោកអ័ប្រាហាំបានរស់នៅសម្រាប់នោះ ។ គ្រប់ទាំងសេចក្តីសន្យានៅក្នុងការតាំងសញ្ញា គឺជាមូលដ្ឋានលើកំណើតរបស់កូនប្រុសគាត់នោះឯង ។ គ្រប់យ៉ាងដែលគាត់បានជឿ គឺរួមជាមួយនឹងលោកអ៊ីសាកដែរ ។ វាគឺជាសកម្មភាពនៃការចុះចូលចំពោះព្រះ ទាំងស្រុងនោះឯង ។

ដោយសារតែការស្តាប់បង្គាប់ របស់លោកអ័ប្រាហាំចំពោះការថ្វាយបង្គំ នោះព្រះទ្រង់បានគង់នៅក្នុងការសរសើរនោះ ហើយក៏បានបំពេញដល់

លោកអ័ប្រាហាំ ក្នុងថ្វាយអ៊ីសាកធ្វើជាយញ្ញបូជានោះ ។

ព្រះគម្ពីរទំនុកដំកើង ២២:៣

លោកអ័ប្រាហាំបាននាំលោកអ៊ីសាក មកថ្វាយជាយញ្ញបូជា ហើយការនេះក៏បានត្រឡប់មកជាគំរូនៃយញ្ញបូជាដ៏ខ្ពស់បំផុត ។ ក្រោយមក យើងបានឃើញព្រះដ៏ជាព្រះវរបិតា ទ្រង់បានបញ្ជូនព្រះរាជបុត្រារបស់ទ្រង់ ព្រះនាមព្រះយេស៊ូវ ឱ្យមកធ្វើជាយញ្ញបូជានោះជាសម្រេច ។ សូម្បីតែមានលទ្ធភាពដ៏ខ្លាំងក្លា ដែលព្រះយេស៊ូវទ្រង់បានត្រូវធ្វើជាយញ្ញបូជា គឺនៅក្នុងទីកន្លែងដែលលោកអ័ប្រាហាំ បានថ្វាយអ៊ីសាក ឱ្យធ្វើជាយញ្ញបូជានោះដែរ ។ យើងត្រូវតែចុះចូលពីគ្រប់ទាំងការសម្រេចចិត្ត ជាលក្ខណៈបុគ្គល មហិច្ឆិតា និងមានផែនការចូលទៅក្នុងការថ្វាយបង្គំដ៏ពិតនោះ ។

## ង. តើអ្វីទៅជាយញ្ញបូជារបស់យើង?

ព្រះគម្ពីររ៉ូម ១២:១-២

វាគឺជាការបម្រើដ៏មានហេតុផលសមរម្យមួយ ។ ចូរកុំត្រាប់តាមលោកិយនេះឡើយ គឺឱ្យមានការផ្លាស់ប្រែវិញ ។ វាគឺជាការស្តាប់បង្គាប់ទាំងស្រុងនោះឯង ។ លោកអ័ប្រាហាំសម្តែងពីការ ចុះចូលដ៏រឹងមាំនេះឯង គឺជាការតម្រូវឱ្យមានសេចក្តីជំនឿដ៏ខ្ពស់បំផុត ។ វាជាការធ្វើដំណើរទៅដោយមានការទាស់ទទឹងនឹងសេចក្តីសន្យារបស់ព្រះឬទេ ។ បើទោះជាយ៉ាងណាក៏ដោយ ក៏លោកអ័ប្រាហាំបាននិយាយដោយសេចក្តីជំនឿថា "កូនរបស់ខ្ញុំនិងខ្ញុំ នឹងវិលត្រឡប់មកវិញ" ។

ការថ្វាយបង្គំ គឺជាការនាំឱ្យយើង ចូលទៅក្នុងសិរីល្អរបស់ផងព្រះ ។ យើងមានសេរីភាពនៅក្នុងព្រះវត្តមាននៃព្រះ ។ យើងត្រូវបានទទួលនូវការគាំទ្រឱ្យបានកាន់តែជិតស្និទ្ធ ដែលមានការផ្ចិតទៅនឹងបុគ្គលិកលក្ខណៈរបស់ទ្រង់ ដែលមិនរលុបគឺដែលបានបង្កើតមកលើវិញ្ញាណរបស់យើងនោះឯង ។ យើងចំណាយពេលនៅក្នុងព្រះវត្តមានរបស់ទ្រង់ច្រើនប៉ុណ្ណា នោះវិញ្ញាណរបស់យើង ក៏បានអនុលោមទៅតាមរូបភាពរបស់ព្រះអង្គច្រើនប៉ណ្ណោះដែរ ហើយជីវិតរបស់យើងក៏មានការផ្លាស់ប្រែ ចូលទៅក្នុងរូបភាពនៃព្រះរាជបុត្រារបស់ទ្រង់ព្រះនាមព្រះយេស៊ូវ ហើយយើងនឹងបានត្រឡប់មកជាដូចព្រះអង្គបានច្រើនប៉ុណ្ណោះដែរ ។

## ច.ឧបករណ៍ភ្លេងសម្រាបការថ្វាយបង្គំ

មានឧបករណ៍ភ្លេងជាច្រើនសម្រាប់ប្រើ ក្នុងការថ្វាយបង្គំនៅក្នុងរោងឧបោសថរបស់ស្តេចដាវីឌ ។

ព្រះគម្ពីរទំនុកដំកើង ១៥០:១-៦

នៅក្នុងបទទំនុកដំកើងខ្លី១មួយនេះ ស្តេចដាវីឌបានចុះក្នុងបញ្ជីឧបករណ៍ភ្លេងទាំង៧ ដែលត្រូវបានប្រើប្រាស់ ក្នុងការសរសើរដល់ព្រះ ។ គឺជា "ឧបករណ៍" ចុងក្រោយ និងសំខាន់៧ សម្រាប់ជួយដល់ការបំពងសម្លេងរបស់យើងគឺ:

**១. ត្រែ ( ត្រុមប៉ែត)**

**២. ពិណ**

**៣. ពិណបុរាណ**

**៤. សំកោរ**

**៥. ប្រដាប់មានខ្សែ**

**៦. ខ្លុយ**

**៧. ឈ្មោះ**

**៨. សម្លេងរបស់យើង**

**ឆ. ចូរយើងថ្វាយបង្គំព្រះដោយវិញ្ញាណ និងសេចក្ដីពិត**

ព្រះគម្ពីរកិច្ចការ ១៣:២

ពេលដែលពួកគេបានបំពេញកិច្ចការងារ ថ្វាយដល់ព្រះ នោះពួកគេត្រូវបានប្រទាន នូវទិសដៅពិសេសដែលមកពីព្រះ ។

**១. ចូរយើងទទួលខុសត្រូវចំពោះព្រះ ឱ្យអស់ពីចិត្តរបស់ផងយើង ។**

ព្រះគម្ពីរទំនុកដំកើង ៤២:១-២

ទូលបង្គំនឹងស្វែងរកព្រះភក្រ្តទ្រង់ ។ ទូលបង្គំនឹងសម្លឹង មើលភាពស្រស់ស្អាតរបស់ទ្រង់ ។ សូមឱ្យទូលបង្គំបាននៅក្រោមម្លប់ នៃព្រះដ៏មានគ្រប់ព្រះចេស្ដា នៅក្នុងទីអាថិកំបាំងនៃព្រះដ៏ខ្ពស់បំផុត ។ មនុស្សនឹងត្រូវបានទទួលការប្រោសឱ្យជា ដោយម្លប់របស់លោកពេត្រុស ដែលជាស្រមោលជះទៅលើពួកគេ ។ ដូច្នេះ សូមឱ្យយើងខ្ញុំបានរស់នៅក្នុងម្លប់របស់ព្រះ និងឱ្យបានជាអ្នកថ្វាយបង្គំដល់ព្រះអង្គទ្រង់ផ្ទាល់ផង ។

**២. លោកម៉ូសេបានចាំងជះ នូវសិរីល្អរបស់ផងព្រះ ។**

លោកម៉ូសេបានចំណាយពេលវេលា ចំនួន៤០ថ្ងៃ ៤០យប់នៅលើភ្នំជាមួយនឹងព្រះ ។ លោកម៉ូសេបានមានការផ្លាស់ប្រែ មុខរបស់គាត់ពេញដោយពន្លឺ ។ គឺមានសិរីល្អយ៉ាងដូច្នោះ មកសណ្ឋិតលើគាត់ ដែលធ្វើឱ្យមនុស្សមិនអាចសម្លឹងមើលមុខគាត់បាន ។

ព្រះគម្ពីរនិក្ខមនំ ៣៤:២៩-៣០

ព្រះគម្ពីរអេសាយ ៦០:១-២

មនុស្សប្រុសត្រូវបានបង្កើតមក ឱ្យមានរូបភាពរបស់ផងព្រះ ។ សិរីល្អនោះឯង ដែលបានបាត់បង់ទៅ គឺនៅពេលដែលលោកអ័ដាម និងនាងអេវ៉ាបានធ្វើបាប ។ គ្រប់ទាំងអស់សុទ្ធតែបានធ្វើបាប ហើយក៏បានធ្លាក់ចុះនូវសិរីល្អរបស់ព្រះ ។ សិរីល្អនោះឯង គឺត្រូវបានរកឃើញ នៅក្នុងព្រះវត្តមានរបស់ព្រះអង្គការគង់នៅក្រោមម្លប់ នៃព្រះដ៏មានគ្រប់ព្រះចេស្ដា ហើយដែលត្រូវបានបំផ្លាស់បំប្រែពីសិរីល្អទៅដល់សិរីល្អ ។ សូមឱ្យយើងបានត្រឡប់ទៅជាអ្នកថ្វាយបង្គំដល់ព្រះ ។ ព្រះវរបិតាទ្រង់បានស្វែងរកអស់អ្នក ដែលថ្វាយបង្គំទ្រង់ដោយវិញ្ញាណ និងសេចក្ដីពិត ។ ដូច្នេះ ចូរមកថ្វាយបង្គំ ហើយស្រូបយកព្រះវត្តមានរបស់ទ្រង់ចុះ ។

## ក្រុមពិភាក្សា

១. ចូរពិភាក្សាថា តើទីបរិសុទ្ធបំផុតដែលនៅផែនដី មានឋានៈស្មើនឹងបល្ល័ង្កនៃព្រះដែលនៅស្ថានសួគ៌ ដោយរបៀបណា ។

២. ព្រះទ្រង់បានសម្រេចព្រះទ័យថា ដែលយើងចូលមកក្នុងព្រះវត្តមានរបស់ទ្រង់ នោះគឺយើងត្រូវតែចាប់យកនូវភាពស្និទ្ធស្នាល ដើម្បីធ្វើយ៉ាងដូច្នោះ ។ តើយើងត្រូវចាប់យកភាពស្និទ្ធស្នាល ដើម្បីចូលមកក្នុងព្រះវត្តមានរបស់ព្រះ ដោយរបៀបណា?

៣. ម្យ៉ាងទៀត យើងបានចូលមកក្នុងព្រះវត្តមានរបស់ព្រះអង្គហើយ នោះយើងមិនត្រូវឆាប់វិលបែរត្រឡប់ទៅវិញនោះឡើយ ។ យើងត្រូវតែរង់ចាំ ឱ្យបានរឹតតែចូលជ្រៅថែមទៀត ។ តើដោយព្រោះហេតុអ្វី?

## ការសិក្សាដោយខ្លួនឯង

១. ក្នុងមួយរំពេចដែលព្រះយេស៊ូវទ្រង់បានចូលទីវង្គត នៅលើឈើឆ្កាង នោះតើហេតុអ្វីបានជាវាំងននក្នុងព្រះវិហារត្រូវរហែកចាប់ពីលើមកដល់ក្រោម?

២. ចូរធ្វើការពណ៌នាដោយពាក្យសម្តី របស់លោកអ្នកផ្ទាល់ ដោយមិនចាំបាច់មើលកំណត់ត្រារបស់លោកអ្នក អំពីការផ្សេងគ្នារវាងការសរសើរ និងការថ្វាយបង្គំនោះ ។

៣. តើវាន័យយ៉ាងដូចម្តេច ចំពោះការថ្វាយបង្គំដោយវិញ្ញាណនោះ?

# ការសរសើរ និងការថ្វាយបង្គំ

## *មេរៀនទី ២: ហេតុអ្វី អ្នកណា ពេលណា ហើយនៅកន្លែងណា*

ព្រះគម្ពីរគឺមានពេញទៅដោយ សេចក្តីបង្រៀនរបស់ព្រះទៅដល់មនុស្សរបស់ព្រះអង្គ ឱ្យបានត្រឡប់មកជាអ្នកសរសើរ និងជាអ្នកថ្វាយបង្គំដល់ទ្រង់ ។ វាគឺជាការសំខាន់ក្នុងការចំណាយពេលវេលាអាន ពីព្រះបន្ទូលទ្រង់ដើម្បីឱ្យពួកគេនឹងបានដឹង:

ហេតុអ្វីដែលយើងត្រូវសរសើរដល់ព្រះអង្គ
អ្នកណាដែលយើងត្រូវសរសើរដល់ព្រះអង្គ
នៅពេលណាដែលយើងត្រូវសរសើរដល់ព្រះអង្គ
នៅកន្លែងណាដែលយើងត្រូវសរសើរដល់ព្រះអង្គ

### I. ចម្លើយទៅនឹងសំណួរទាំងឡាយនេះ

### ក. ហេតុអ្វីបានជាយើងត្រូវតែសរសើរដល់ព្រះ?

**១. គឺដោយសារតែទ្រង់មានតម្លៃខ្ពស់ត្រូវតែអរព្រះគុណ**

ព្រះគម្ពីរទំនុកដំកើង ១០៧:១,២៨

**២. គឺដោយសារតែទ្រង់មានតម្លៃខ្ពស់ត្រូវតែសរសើរ**

ព្រះគម្ពីរ ២សាំយូអែល ២២:៤

**៣. គឺដោយសារតែទ្រង់ធំអស្ចារ្យ**

ព្រះគម្ពីរទំនុកដំកើង ៤៨:១

ព្រះគម្ពីរទំនុកដំកើង ៩៦:៤

**៤. គឺដោយសារតែទ្រង់មានសកម្មភាពដ៏មានឫទ្ធិចេស្តា**

ព្រះគម្ពីរទំនុកដំកើង ១៥០:២

**៥. គឺដោយសារតែទ្រង់បានជ្រើសរើសយើង**

ព្រះគម្ពីរលូកា ១០:២០

**៦. ទ្រង់ជាព្រះដ៏មានសិរីល្អ**

ព្រះគម្ពីរទំនុកដំកើង ៥០:២៣

ព្រះគម្ពីរទំនុកដំកើង ៦៩:៣០

**៧. យើងត្រូវទទួលបញ្ជាឱ្យសរសើរ**

ក. តាមរយៈស្តេចដាវីឌ

ព្រះគម្ពីរទំនុកដំកើង ១៤៩:១

ខ. តាមរយៈលោកសាវ័កប៉ុល

ព្រះគម្ពីរអេភេសូរ ៥:១៩

គ. តាមរយៈលោកសាវ័កយ៉ូហាន

ព្រះគម្ពីរវិវរណៈ ១៩:៥

**៨. គឺដោយសារតែទ្រង់ល្អអស្ចារ្យ**

ព្រះគម្ពីរទំនុកដំកើង ៩២:១-២

**៩. គឺដោយសារតែគាប់ដល់ព្រះហឫទ័យទ្រង់**

ព្រះគម្ពីរទំនុកដំកើង ១៤៧:១

**១០. គឺដោយសារតែវាជាការមានសោភណភាព**

ព្រះគម្ពីរទំនុកដំកើង ៣៣:១

**១១. តើការសរសើរជាសេចក្តីថ្លៃថ្នូរឬទេ?**

មានការកោតខ្លាចមួយ នៃការសរសើរព្រះចំពោះអ្នកខ្លះ គឺដោយសារតែពួកគេមិនមានអារម្មណ៍ថា វាគឺជាសេចក្តីថ្លៃថ្នូរ ។ នេះគឺជាការជំទាស់ទៅនឹងព្រះបន្ទូលរបស់ព្រះហើយ ។

ព្រះគម្ពីរ ២សាំយូអែល ៦:១៤-១៦,២១-២៣

**១២. ព្រះទ្រង់គង់នៅក្នុងការសរសើរ ។**

ព្រះគម្ពីរទំនុកដំកើង ២២:៣

ប្រសិនបើចិត្តរបស់យើង មានពេញដោយការសរសើរ នោះពួកគេក៏ត្រូវបានបំពេញដោយសារ

ព្រះផងដែរ ។ ប្រសិនបើផ្ទះរបស់យើងមានពេញ ដោយការសរសើរ នោះពួកគេនឹងត្រូវបានបំពេញ ដោយព្រះផងដែរ ។ យើងអាចនឹងមានការចុះចូល ដោយខ្លួនយើង ដោយមានព្រះវត្តមានរបស់ព្រះ គឺ ដោយការចុះចូលក្នុងការសរសើរនោះឯង ។

**១៣.ការសរសើរគឺជាការបញ្ចេញនូវកម្លាំង ។**

ព្រះគម្ពីរនេហេមា ៨:១០ខ

ព្រះគម្ពីរទំនុកដំកើង ២៨:៧

**១៤. ការសរសើរគឺនាំមកនូវការបានសម្រេច ។**

ព្រលឹងដែលសរសើរ នោះគឺមានអំណរនៅក្នុង ព្រះអម្ចាស់ ហើយព្រះទ្រង់ក៏ប្រទានឱ្យគេមានចិត្ត របស់ទ្រង់ដ៏យូរអង្វែង ។

ព្រះគម្ពីរទំនុកដំកើង ៣៧:៤

ចូរកំណត់ចំណាំថា ការសរសើរ គឺត្រូវតែចូល មកជាដំបូង មុនពេលដែលយើងបានទទួល ។ រឿង នោះគឺដោយសារតែការសរសើរ ដែលបានដាក់ចូល ទៅក្នុងឯកសិទ្ធិរបស់យើងជាលំដាប់លំដោយ ហើយ បន្ទាប់មកព្រះទ្រង់ក៏អាចវែងយើង ទៅតាមការ សម្រេចចិត្តចេញពីចិត្តរបស់យើងដែរ ។

**១៥.ការសរសើរគឺនាំមកនូវជ័យជម្នះ ។**

ព្រះគម្ពីរទំនុកដំកើង ១៨:៣

ព្រះគម្ពីរ ២របាក្សត្រ ២០:២១-២២

ស្តេចយ៉ូសាផាត និងពួកទាហានអ៊ីស្រាអែល គឺ ត្រូវបានចុះចូលដោយពួកកងទ័ពទាំងបីក្រុម ។ ពេល ដែលពួកគេបានចាប់ផ្តើមច្រៀងសរសើរ ដល់ព្រះ យេហូវ៉ា នោះព្រះយេហូវ៉ាក៏បានបណ្តាលឱ្យមានការ ពួនស្ទាក់វាយ ហើយពួកកងទ័ពទាំងបីក្រុមនោះ ក៏ត្រូវទទួលការបរាជ័យ ។ សូម្បីតែការរស់នៅរបស់ យើងនៅក្នុងសមរភូមិជារៀងរាល់ថ្ងៃក៏ដោយ ក៏ការ សរសើរអាចដឹកនាំផ្លូវយើងឱ្យមានជ័យជម្នះដែរ ។

**ខ. តើអ្នកណាត្រូវសរសើរដល់ព្រះ?**

**១. គ្រប់ទាំងសាច់**

ព្រះគម្ពីរទំនុកដំកើង ១៤៥:២១ខ

**២. ព្រលឹងរបស់ខ្ញុំ**

ព្រះគម្ពីរទំនុកដំកើង ១០៣:១-២

**៣. គ្រប់ទាំងអស់ដែលមានដង្ហើម**

ព្រះគម្ពីរទំនុកដំកើង ១៥០:៦

**៤. គ្រប់មនុស្សទាំងអស់**

ព្រះគម្ពីរទំនុកដំកើង ៦៧:៣,៥

ព្រះគម្ពីរទំនុកដំកើង ៧៨:៤

ព្រះគម្ពីរទំនុកដំកើង ៧៩:១៣

**៥. ពួកអ្នកសុចរិត**

ព្រះគម្ពីរទំនុកដំកើង ១៤០:១៣

**៦. ពួកបរិសុទ្ធ**

ព្រះគម្ពីរទំនុកដំកើង១៤៥:១០

**៧. ពួកអ្នកបានទទួលការប្រោសលោះ**

ព្រះគម្ពីរទំនុកដំកើង ១០៧:១-២

**៨. អស់អ្នកដែលកោតខ្លាចព្រះ**

ព្រះគម្ពីរទំនុកដំកើង ២២:២៣

**៩. ពួកអ្នកបម្រើព្រះ**

ព្រះគម្ពីរទំនុកដំកើង ១១៣:១

ព្រះគម្ពីរទំនុកដំកើង ១៣៤:១

ព្រះគម្ពីរទំនុកដំកើង ១៣៥:១

**១០. ពួកទេវតាទាំងអស់របស់ទ្រង់**

ព្រះគម្ពីរទំនុកដំកើង ១៤៨:២

**១១. ធម្មជាតិទាំងអស់**

ព្រះគម្ពីរទំនុកដំកើង ១៤៨:៧-១០

**១២. ស្តេច និងប្រជារាស្ត្រ**

ព្រះគម្ពីរទំនុកដំកើង ១៤៨:១១-១៣

### គ.តើនៅពេលណាដែលយើងត្រូវសរសើរដល់ព្រះ?

**១. ចាប់ពីព្រឹកដល់យប់**

ព្រះគម្ពីរទំនុកដំកើង ១១៣:៣

**២. រាល់ថ្ងៃទាំងអស់**

ព្រះគម្ពីរទំនុកដំកើង ៧១:៨

**៣. ពេលដែលយើងរស់នៅ**

ព្រះគម្ពីរទំនុកដំកើង ១៤៦:២

ការសរសើរនៅគ្រប់ពេល គឺមិនត្រឹមតែនៅពេលដែលរឿងរ៉ាវទាំងឡាយសុទ្ធតែល្អនោះទេ ។

**៤. នៅតែបន្ត**

ព្រះគម្ពីរទំនុកដំកើង ៣៤:១

**៥. នៅពេលដែលអស់កម្លាំង**

ព្រះគម្ពីរទំនុកដំកើង ៤២:១១

ក្នុងពេលលំបាកបំផុតក៏ត្រូវតែសរសើរព្រះ គឺពេលដែលមានការលំបាកនោះឯង ។

**៦. គ្រប់ពេលជានិច្ច**

ព្រះគម្ពីរអេភេសូរ ៥:២០

### ឃ. កន្លែងណាដែលយើងត្រូវសរសើរដល់ព្រះ?

**១. នៅក្នុងព្រះវិហារ**

ព្រះគម្ពីរទំនុកដំកើង ២២:២២,២៥

ព្រះគម្ពីរទំនុកដំកើង ១០៧:៣២

ព្រះគម្ពីរទំនុកដំកើង ១៤៩:១

**២. នៅក្នុងទីលាក់កំបាំង**

ព្រះគម្ពីរទំនុកដំកើង ១៥០:១

**៣. ក្នុងចំណោមជនជាតិទាំងឡាយ**

ព្រះគម្ពីរទំនុកដំកើង ៥៧:៩

**៤. ក្នុងទីលានរបស់ទ្រង់**

ព្រះគម្ពីរទំនុកដំកើង ១០០:៤

**៥. ក្នុងចំណោមហ្វូងមនុស្ស**

ព្រះគម្ពីរទំនុកដំកើង ១០៩:៣០

## II. ពាក្យ “សរសើរ” ដែលបានបកប្រែនៅគ្រាសញ្ញាចាស់

ពាក្យនៅក្នុងភាសាហេព្រើរ ដែលមានចំនួនផ្សេងគ្នា និងច្បាស់ៗ គឺត្រូវបានគេប្រើក្នុងការពណ៌នាពីការសរសើរនៅក្នុងគ្រាសញ្ញាចាស់ ។ ការសិក្សាពីពាក្យទាំងនេះ គឺបើកសម្តែងពីការយល់ដឹងច្បាស់លាស់ជាជាងអ្វី ដែលមានន័យចំពោះការសរសើរដល់ព្រះ នៅសម័យសព្វថ្ងៃនេះទៅទៀត ។

ពាក្យជាភាសាហេព្រើរសម្រាប់ “សរសើរ” គឺបានចង្អុលបង្ហាញ ពីការរាំជួយ និងសកម្មភាពបានយ៉ាងច្រើន ។

### ក. ហាឡាល (Halal)

ពាក្យ “ហាឡាល” គឺត្រូវបានគេប្រើជាញឹកញាប់បំផុតក្នុងការបកប្រែមកជាពាក្យសរសើរនេះ ។ វាបានលេចឡើង

ចំនួន១៦០ដង នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ មានន័យថាៈ ការសរសើររបស់ទ្រង់ គឺបានមកពីព្រះអង្គ (ដោយវិញ្ញាណ និងសេចក្ដីពិត) ។

**១. បង្កើតនូវការបង្ហាញ**

ព្រះគម្ពីរទំនុកដំកើង ២២:២២

**២. ការអំនួត**

ព្រះគម្ពីរទំនុកដំកើង ១០២:១៨

**៣. ពិធីបុណ្យ**

ព្រះគម្ពីរទំនុកដំកើង ៣៥:១៨

**៤. ការសរសើរហួសហេតុអំពី**

ព្រះគម្ពីរទំនុកដំកើង ១០៧:៣២

**៥. សិរីល្អនៅក្នុង**

ព្រះគម្ពីរទំនុកដំកើង ៦៤:១០

**៦. ការចាំងជះពន្លឺ**

ព្រះគម្ពីរទំនុកដំកើង ៤១:១៨

ការសរសើរដ៏ពិត គឺនៅចំពោះដែលត្រូវតែឱ្យមានសម្លេងច្បាស់លាស់ ។ គឺមិនត្រូវមានការភាន់ច្រឡំពីអ្វីទៅខាងមុខនោះឡើយ ។ វាគឺជាកំណត់ត្រានៃពិធីបុណ្យសេចក្ដីអំនួតនៅក្នុងព្រះអម្ចាស់ ។

ព្រះគម្ពីរ ២របាក្សត្រ ២០:២១-២២

## ខ.តេហ៊ីលឡា (Tehillah)(ពាក្យក្លាយមកពី ហាឡាល)

ការបញ្ជាក់របស់ពាក្យ "តេហ៊ីលឡា" គឺសំដៅទៅលើការច្រៀង ។ វាត្រូវបានគេប្រើចំនួន៥៧ដង នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។

**១. គឺជាការឱ្យអត្ថន័យទៅលើការច្រៀងនូវចម្រៀងសរសើរដ៏ច្បាស់លាស់ ។**

ព្រះគម្ពីរទំនុកដំកើង ១១៩:១៧១

**២. គឺជាការធ្វើបុណ្យសម្រាប់ព្រះអង្គ ដោយនូវចម្រៀង**

ព្រះគម្ពីរហាបាគុក ៣:៣

**៣. ថ្លែងការអួតពីទ្រង់**

យើងត្រូវតែអួតពីទ្រង់ដោយពាក្យនិយាយ និងប្រគំតន្ត្រី ព្រមទាំងការច្រៀង ។

ព្រះគម្ពីរចោទិយកថា ១០:២១

## គ. ថ្ងៃសាបាត់

**១. ស្រែកច្រៀងដោយសម្លេងព្ធ១**

ព្រះគម្ពីរទំនុកដំកើង ៦៣:៣

**២. ស្រែកប្រកបដោយជ័យជម្នះ**

ព្រះគម្ពីរដានីយ៉ែល ២:២៣

**៣. ថ្វាយសិរីល្អដោយនូវជ័យជម្នះ**

ព្រះគម្ពីរទំនុកដំកើង ១១៧:១

ការសរសើរគឺមិនមែនជាសេចក្ដីត្រូវការ ឱ្យមានសម្លេងរំពងខ្លាំងៗជានិច្ចកាលនោះទេ ។ យើងក៏មិនមែនត្រូវការស្រែកជានិច្ចកាលនោះដែរ គឺវាមានពេលសម្រាប់ការហាត់សមជាសំខាន់ ក្នុងការសរសើរព្រះផងដែរ ។ វាគឺជាសិទ្ធិក្នុងការសម្ដែង ។

ព្រះគម្ពីរទំនុកដំកើង ៤៧:១

## ឃ. ហ្សាម៉ារ (Zamar)

**១.ការប៉ះពាល់ ឬលេងដោយខ្សែ**

**២. ក៏មានវិញ្ញាណនៃការច្រៀងសរសើរ ដូចជាការបន្ទរតាមឧបករណ៏ភ្លេងជាដើម ។**

ព្រះគម្ពីរទំនុកដំកើង ១០៨:១-៣

**ង.យ៉ាដាហ**(Yadah)

**១. ផ្ដល់ឱ្យនូវការថ្លែងអរព្រះគុណជាបន្ត**

ព្រះគម្ពីរទំនុកដំកើង ១០៩:៣០

**២. ក៏មានការគិតពីការថ្វាយនូវអំណរគុណ ដោយលើកដៃចុះចូលចំពោះ ។**

ព្រះគម្ពីរទំនុកដំកើង ៣៣:២

**៣. ការចុះចូល**

ព្រះគម្ពីរ ២របាក្សត្រ ៧:៣

**ច. តូវដាហ** (Towdah)

ពាក្យ "តូវដាហ" ពីមកពីឫសគល់ដូចគ្នា គឺជាពាក្យ "យ៉ាដាហ" ហើយមានន័យថា:

**១. ការលាតដៃដោយគោរព និងដោយអរព្រះគុណ ។**

ព្រះគម្ពីរទំនុកដំកើង ៤២:៤

**២. ការថ្វាយយញ្ញបូជាដោយការទទួលស្គាល់ និងចុះចូល**

ព្រះគម្ពីរទំនុកដំកើង ៥០:២៣

**ឆ.បារ៉ាក**(Barak)

**១. ការលុតជង្គង់ចុះដោយគោរព**

ព្រះគម្ពីរទំនុកដំកើង ៩៥:៦ខ

**២. ការលុតជង្គង់ចុះនៅចំពោះអ្នកខ្លះ ក្នុងការបន្ទាបខ្លួនជាក់ស្ដែង និងក្នុងការសម្ដែងពីតម្លៃ និងតួនាទីដ៏ឧត្តុង្គឧត្តម ។**

**ជ. សាចាហ**(Shachah)

នៅពេលដែលគេប្រើពាក្យជាភាសាហេព្រើរនោះត្រូវបានបកប្រែថា "ថ្វាយបង្គំ" មានតែពាក្យជាភាសាហេព្រើរតែមួយគត់ ដែលត្រូវបានប្រើនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដើម្បីបញ្ជាក់ពីការថ្វាយបង្គំដល់ព្រះ ។

**សាចាហ** មានន័យថា អស់អ្នកដែលក្រាបចុះនៅចំពោះព្រះ ដោយការថ្វាយបង្គំ និងការគោរព ។ វាក៏ត្រូវបានចង្អុលបង្ហាញផងដែរ នូវអាកប្បកិរិយារបស់ចិត្ត សូម្បីតែរូបកាយរបស់មនុស្សណាម្នាក់ ដែលមិនបានឱនលំទោនក៏ដោយ ។

ព្រះគម្ពីរទំនុកដំកើង ៩៥:៦

ចូរយើងលុតជង្គង់ចុះ នៅចំពោះព្រះដ៏ជាអ្នកកត់ចំណាំនៃយើង ។

**III. ការរុករកឱ្យឃើញនូវការសរសើរ និងការថ្វាយបង្គំចេញមកពីពាក្យជាភាសាហេព្រើរ**

**ក. ការចង្អុលបង្ហាញខាងរូបកាយ**

ការសរសើរគឺជាការចង្អុលបង្ហាញខាងរូបកាយទៅចំពោះអាកប្បកិរិយាខាងវិញ្ញាណ គឺជាការទទួលខុសត្រូវផ្នែកខាងក្នុងចិត្ត ក្នុងការបើកសម្ដែងរបស់ព្រះ និងភាពដ៏អស្ចារ្យរបស់ផងទ្រង់ ។

សកម្មភាពខាងរូបកាយគឺតែងតែមានការសរសើរ គឺជារឿងរ៉ាវដែលយើងធ្វើ ។ វារួមបញ្ចូលទាំងការបើកបង្ហាញការធ្វើពិធីបុណ្យ ការថ្វាយសិរីល្អ ការរវើរវាយ ការលេងភេងការលើកដ និងការលុតជងង់ចុះ ។ ការសរសើរដ៏ពិតគឺត្រូវតែមានការបើកសម្ដែង ។

### ខ.ការចង្អុលបង្ហាញពីការបញ្ចេញសម្លេង

ការសរសើរដ៏ច្រើនលើសលុប គឺមានការចូលរួមនឹងការចង្អុលបង្ហាញពីការបញ្ចេញសម្លេង ។ ចម្រៀងនៃការសរសើរដ៏ច្បាស់លាស់ គឺជាការផលិតនូវសម្លេង ការអួត ការច្រៀង ការស្រែកដោយសម្លេងខ្លាំង ការផ្តល់ឱ្យនូវសម្រែកជ័យជម្នះ និងការផ្តល់ឱ្យនូវការថ្លែងអរព្រះគុណដល់ព្រះបានយ៉ាងច្បាស់លាស់ ។

### គ. ការបញ្ចេញអារម្មណ៍

ការសរសើរគឺអាចត្រូវបាន ជាការបញ្ចេញនូវអារម្មណ៍ ។ ការសរសើរព្រះ គឺមិនមែនជាការហាត់សមនូវអារម្មណ៍នោះទេ គឺជាសកម្មភាពខាងវិញ្ញាណវិញ ។

ការសរសើដ៏ពិតនឹងតែងតែនាំមក នូវការបញ្ចេញអារម្មណ៍ ។

អារម្មណ៍គឺមិនមែនជាការសំខាន់ទៅលើសាច់ឈាម ឬខាងផ្នែករូបសាច់នោះទេ ។

ព្រះទ្រង់បានប្រទានឱ្យយើងនូវអារម្មណ៍ ហើយពួកវាគឺត្រូវតែបានគេប្រើក្នុងការថ្វាយសិរីល្អដល់ព្រះអង្គ ។ អារម្មណ៍គឺរួមបញ្ចូលទាំងការធ្វើពិធីបុណ្យ ការរវើរវាយ និងការផ្តល់ឱ្យនូវការចង្អុលបង្ហាញ ដោយការស្រែកខ្លាំងៗ ។

### ឃ. ការគោរពដ៏ជ្រាលជ្រៅ

ការសរសើរគួរតែបានធ្វើរួចហើយ ខាងភ្នែកអាកប្បកិរិយានៃការគោរពដ៏ជ្រាលជ្រៅនោះ ។ ការគោរពដ៏ជ្រាលជ្រៅមានន័យថា កិត្តិយស និងការរាប់អានពីអ្នកណាម្នាក់ដ៏សមរម្យ ។

សកម្មភាពនៃការសរសើរ គឺមិនដែលបានអនុញ្ញាតឱ្យមានភាពអាប់ឱនចូលទៅក្នុងការហួសកំណត់ នៅខាងក្រៅព្រំដែននៃការចាក់ប្រេងតាំង និងការបង្ហូរមកនៃព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងអង្គប្រជុំពិសេសមួយនោះជាដើម ។

ការសរសើរព្រះដ៏គ្មានព្រំដែន គឺមានន័យថា ជាសេចក្តីអំណរដោយខ្លួនឯង វាត្រូវតែបានផ្តល់ឱ្យនូវការចង្អុលបង្ហាញទៅលើការគោរពដ៏ជ្រាលជ្រៅ ព្រមទាំការអរព្រះគុណដល់ព្រះនោះឯង ។

### ង.សេចក្តីសរុបបញ្ចប់

យើងក៏អាចប្រមូលនូវសេចក្តីសរុបបញ្ចប់ ចេញពីពាក្យជាភាសាហេព្រើរទាំងនេះ ។

ព្រះទ្រង់ជាវិញ្ញាណ ហើយយើងត្រូវថ្វាយបង្គំទ្រង់ ដោយវិញ្ញាណ និងសេចក្តីពិត ។

ការសរសើរគឺអាចជាអារម្មណ៍ ប៉ុន្តែ យើងត្រូវតែរវាងមើលការដែលទាស់ប្រឆាំងនឹងការសរសើរ ដែលមានសេចក្តីអំណរមកពីសាច់ឈាមផងដែរ ។ វាត្រូវតែមានការសរុបដោយនូវព្រះវិញ្ញាណ មិនមែនជាការបើកសម្តែងពីសាច់ឈាមនោះទេ ។

ព្រះគម្ពីរយ៉ូហាន ៤:២៣-២៤

ព្រះទ្រង់ជាព្រះវរបិតារបស់យើង ដែលទ្រង់បានស្វែងរកអស់អ្នកដែលនឹងថ្វាយបង្គំទ្រង់ ដោយវិញ្ញាណ និងសេចក្តីពិតនោះឯង ។ តើលោកអ្នកនឹងទទួលខុសត្រូវដោយរបៀបណា? ការសម្រេចចិត្តរបស់ខ្ញុំ គឺត្រូវតែថ្វាយបង្គំព្រះអង្គ ។ យើងមានឯកសិទ្ធិក្នុងការបានសម្រេច ដែលបានមកពីព្រះទ័យនៃព្រះវរបិតារបស់យើង ។ បន្ទាប់មក ព្រះទ្រង់បានគង់នៅក្នុងការសរសើររបស់យើង ហើយក៏បានបំផ្លាស់បំប្រែយើងឱ្យចូលទៅក្នុងរូបភាពរបស់ព្រះអង្គ ។

## ក្រុមពិភាក្សា

១. ហេតុអ្វីបានជាត្រូវតែបានទទួលនូវការបើកសម្ដែង ពីការសរសើរដ៏ពិតប្រាកដ?

២. ចូរប្រឹក្សាឱ្យបានរឹតតែជ្រៅទៀត ពីអ្វីដែលមានន័យ ថាលុតជង្គង់ចុះចំពោះអ្នកណាម្នាក់ ។

៣. ហេតុអ្វីបានជាព្រះទ្រង់បានបញ្ជាយើង ឱ្យសរសើរ (ទំនុកដំកើង ១៤៩:១ អេភេសូរ ៥:១៩ និងវិវរណៈ ១៩:៥)?

## ការសិក្សាដោយខ្លួនឯង

១. ការសរសើរគឺត្រូវតែបានផ្ដល់មកឱ្យ ពីការចង្អុលបង្ហាញនូវការគោរពដ៏ជ្រាលជ្រៅ ព្រមទាំងការថ្លែងអំណរព្រះគុណចំពោះព្រះ ។ តើមនុស្សម្នាក់អាចធ្វើការនេះឱ្យបានច្បាស់លាស់ដោយរបៀបណា?

២. ពាក្យនីមួយៗនៅក្នុងភាសាហេព្រើរ សម្រាប់ពាក្យ "សរសើរ" ដែលលោកអ្នកបានសិក្សារៀនសូត្រមកនេះ គឺជានិយមន័យដ៏ជាទីគាប់ចិត្តរបស់លោកអ្នក ។ ហេតុអ្វី?

៣. តើអ្វីទៅជាការសម្រេចចិត្តរបស់លោកអ្នក? ចូរធ្វើការអធិស្ឋានទូលសូមទៅព្រះ ឱ្យទ្រង់បានដឹកនាំបន្ថែមទៀតចូលទៅក្នុងការថ្វាយបង្គំព្រះដោយវិញ្ញាណ និងសេចក្ដីពិត ។

# ការសរសើរ និងការថ្វាយបង្គំ

## *មេរៀនទី ៣ៈ គោលបំណងដ៏អស់កល្បរបស់ព្រះ*

### I. មានពាក្យនៅក្នុងព្រះគម្ពីរបន្ថែមទៀត

### ក. ពាក្យដែលបកប្រែថា សរសើរ និង ថ្វាយបង្គំ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី

មានពាក្យច្រើនជាភាសាក្រិក ដែលត្រូវបានប្រើក្នុងការពណ៌នាពីការសរសើរ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ ការសិក្សានូវពាក្យទាំងនេះនឹងបើកឱ្យយើង ក្នុងការធ្វើសកម្មភាពបន្ថែមទៀត និងការចង្អុលបង្ហាញនូវការសរសើរព្រះរបស់យើង ។

១. **អាយនេអូ** (Aineo)

ក. ដង្ហាយ ឬពិធីនៃការសរសើរ

ព្រះគម្ពីររ៉ូម ១៥:១១

ខ. ការលើកសម្លេងចុះឡើងក្នុងការអរព្រះគុណ

ព្រះគម្ពីរលូកា ១៩:៣៧

២. **អេប៉ាយនេអូ** (Epaineo)

ក. ដោយទះដៃសាទរ

ព្រះគម្ពីរ ១ពេត្រុស ១:៧

ខ. ការលើកតម្កើងដល់

ព្រះគម្ពីរអេភេសូរ ១:៦

៣. **អេឡូហ្សេអូ** (Eulogeo)

មានន័យថា និយាយល្អចំពោះ ឬធ្វើសំកថា

ព្រះគម្ពីរលូកា ១:៦៤

៤. **ដុកសា** (Doxa)

អត្ថន័យពាក្យ "ថ្វាយសិរីល្អ" ។ យើងមានការទំនាក់ទំនងជាមួយនឹងពាក្យ "ដុកសូឡូជី": ថ្វាយសិរីល្អដល់ព្រះ ។

ពាក្យ ដុកសា គឺបានចង្អុលប្រាប់បន្ថែមទៀតទៅលើបរិយាកាស ដែលបានបង្កើតមកដោយការថ្វាយបង្គំ ជាជាងការចង្អុលបង្ហាញខាងផ្នែករូបកាយ ។

ព្រះគម្ពីរយ៉ូហាន ៩:២៤ក

៥. **ប្រូសគូនេអូ** (Proskuneo)

ការក្រាបចុះ

ប្រូសគូនេអូ គឺមានន័យថា "ឱនលំទោនដោយថ្វាយសក្ការបូជា" ។

ព្រះគម្ពីរម៉ាថាយ ២:២

### ខ.និយមន័យនៃកាលកំណត់ក្នុងព្រះគម្ពីរ

**១. ទំនុកដំកើង**

ពាក្យទំនុកដំកើង គឺបានមកពីពាក្យជាភាសាក្រិកថា "ផ្សុមម៉ូស" (psalmos)។ វាមានន័យជាទូទៅគឺ "ទំនុកដែលផ្សំឡើងដើម្បីច្រៀង" ។

**២. "ផ្សុមម៉ូស"** (psalmos)

ពាក្យ "ផ្សុមម៉ូស" គឺជាទំនុកដំកើងដែលមានការប្រគុំបទភ្លេង ។ អត្ថន័យដើមរបស់វាគឺ "ញាក់ ឬកន្ត្រាក់ជាមួយនឹងម្រាមដៃទៅលើខ្សែ ដែលជាឧបករណ៍ភ្លេង ជាមួយនឹងពិណ" ។

**៣. ចម្រៀងទំនុកដំកើង**

ចម្រៀងទំនុកដំកើង គឺចេញមកពីពាក្យភាសាក្រិក "ហាំម៉ែនស"(humans) គឺមានន័យថា

ចម្រៀងនៃការសរសើរដល់ព្រះ ឬជាពាក្យដែលមកពីភាសាក្រិកថា "ហាំនេអូ"(humneo) មានន័យថា "ច្រៀងចម្រៀងនៃការសរសើរមួយបទថ្វាយព្រះ" ។

### ៤. ចម្រៀងខាងឯវិញ្ញាណ

ពាក្យជាភាសាក្រិក "ព្នឺម៉ាទីកុស អូដេ" (ចម្រៀងខាងឯវិញ្ញាណ) (pneumatikos ode) មានន័យថា "ចម្រៀងចេញមកដោយឯង១ ដែលមានពាក្យ និងបទភ្លេងដែលបានប្រទានមកនៅពេលតែមួយ ដោយព្រះវិញ្ញាណបរិសុទ្ធ" ។

ព្រះទ្រង់សព្វព្រះទ័យចង់ប្រទានឱ្យយើង នូវចម្រៀងថ្មី គឺជាការបញ្ជាក់បង្ហាញពីចិត្តរបស់យើងនៅក្នុងពេលភ្លាម១ ។

## II. គោលបំណងដ៏អស់កល្បរបស់ព្រះសម្រាប់ការសរសើរ

យើងរាល់គ្នាត្រូវបានបង្កើតមកសម្រាប់ការសរសើរ និងការថ្វាយបង្គំ ។ ការសម្រេចចិត្តដ៏ធំបំផុតនៃជីវិតរបស់យើងនោះគួរគប្បីឱ្យបានសរសើរ និងថ្វាយបង្គំដល់ព្រះ ។ ចំពោះហេតុផលដែលយើងរស់នៅ នោះគួរគប្បីត្រូវថ្វាយបង្គំដល់ព្រះអង្គ ។ លោកសាវ័កយ៉ូហាន បានប្រាប់យើងថា ព្រះទ្រង់បានស្វែងរកសម្រាប់កូនប្រុសស្រី ឱ្យបានថ្វាយបង្គំទ្រង់!

ព្រះគម្ពីរយ៉ូហាន ៤:២៣

### ក. ព្រះទ្រង់មានសេចក្តីអំណរជាមួយនឹងការច្រៀង ។

ព្រះអង្គទ្រង់មានសេចក្តីអំណរ មកលើយើងដោយមានចម្រៀងនោះឯង!

ព្រះគម្ពីរសេផានា ៣:១៧

ពាក្យជាភាសាហេព្រើរ បានប្រើក្នុងការពិពណ៌នាពីសកម្មភាពរបស់ព្រះ ដោយមានសេចក្តីអំណរ គឺមានន័យថា "លោតឡើងលោតចុះ និងបង្វិលជុំវិញ ដោយសេចក្តីរំជួយដែលសម្តែងសេចក្តីសប្បាយរីករាយក្រៃលែង" ។

យើងអាចទូលសួរថា "ហេតុអ្វីបានជាព្រះទ្រង់បានរំភើបចិត្តជាមួយនឹងយើងខ្ញុំ គឺដែលទ្រង់មានសេចក្តីអំណរ ទាំងលោតឡើងលោតចុះ ទាំងបង្វិលជុំវិញ ដោយសេចក្តីរំជួយដែលសម្តែងសេចក្តីសប្បាយរីករាយក្រៃលែងដល់ម្ល៉េះ?"

ដើម្បីឱ្យបានយល់ពីចម្លើយចំពោះសំណួរនេះ គឺយើងត្រូវការត្រឡប់ទៅឯអតីតកាលដ៏អស់កល្ប និងមានការយល់ដឹងពីមុខងារនៃការសរសើរ និងការថ្វាយបង្គំដោយពួកទេវតា ។

### ខ.ពួកទេវតាដែលបានបង្កើតឡើង

តាំងពីអស់កល្បរៀងមក ពួកទេវតាត្រូវបានបង្កើតឡើងដោយព្រះសម្រាប់ឱ្យមានមុខងារច្បាស់លស់ ។ ពួកទេវតាទាំងសល់សែន គឺហាក់ដូចជាមានអ្នកដឹកនាំមានមេបីក្រុម ។

#### ១. មហាទេវតាមីកែល

គឺជាអ្នកដឹកនាំក្រុមធំ នៃពួកទេវតាជាអ្នកចម្បាំង ។ គាត់ និងពួកទេវតារបស់គាត់ បានហោះហើរប្រឆាំងនឹងនាគពីបុរាណ ហើយក៏បានបណ្តេញវាចេញពីស្ថានសួគ៌មក ។

#### ២. ទេវតាកាព្រីយ៉ែល

គឺជាអ្នកដឹកនាំពួកទេវតា ក្នុងការបញ្ជូនព្រះរាជសារ ហើយក៏មានការស្មោះត្រង់ចំពោះព្រះ ។ ពួកគេបានលេចមក ជាមួយនឹងព្រះរាជសារនៃដំណឹងល្អរបស់ព្រះ ។

### ៣. ទេវតាលូស៊ីហ្វើរ

គឺជាអ្នកដឹកនាំពួកទេវតា ដែលបានបង្កើតមកពិសេសសម្រាប់សរសើរ និងថ្វាយបង្គំ គឺជាអ្នកគ្របបាំង និងការពារបល្ល័ង្ករបស់ព្រះ ។

## គ. លូស៊ីហ្វើរ គឺជាចេរូប៊ីនយាមល្បាត

ព្រះទ្រង់បានបង្កើតទេវតាលូស៊ីហ្វើរមក ឱ្យធ្វើជាចេរូប៊ីនអ្នកយាមល្បាត ការពារបល្ល័ង្ករបស់ព្រះ ។

ព្រះគម្ពីរអេសេគាល ២៨:១៤

នៅពេលដែលចេរូប៊ីនបានគ្របបាំង ទីសន្តោសប្រោសគឺជាហិបនៃសេចក្ដីសញ្ញា ដោយស្លាបរបស់ពួកគេ សូម្បីតែលូស៊ីហ្វើរនៅបន្ទាប់ពីបល្ល័ង្ករបស់ព្រះ "គឺជាអ្នកទទួលការចាក់ប្រេងតាំងជាចេរូប៊ីន ធ្វើជាអ្នកគ្របបាំងក៏ដោយ" ក៏វាចង់បានធ្វើធំស្មើព្រះដែរ ។

### ១. អត្ថន័យនៃឈ្មោះ

នៅក្នុងភាសាហេព្រើរ ពាក្យលូស៊ីហ្វើរគឺ "ហេឡែល" (heylel)។ វាមកពីឫសគល់ពាក្យ "ហាឡាល" (halal) គឺជាពាក្យដែលចេញមកពី "ហាលេលូយ៉ា" (hallelujah) ។ មានន័យថា សរសើរ ភាពមានពន្លឺ បញ្ចេញពន្លឺ ប្រសើររុងរឿង ពិធី សិរីល្អ និងមានការល្បីឈ្មោះ ។

ពាក្យលូស៊ីហ្វើរ គឺជាពាក្យ "ហាលេលូយ៉ា" ជាពាក្យសរសើរដើម ដែលជាអ្នកបានរៀបចំធ្វើពិធីភ្លឺចាំងជាសិរីល្អរបស់ព្រះយេហូវ៉ា ។

### ២. ត្រូវបានបង្កើតមកសម្រាប់លេងភ្លេង

ព្រះគម្ពីរអេសាយ ១៤:១១ក,១២ក

លូស៊ីហ្វើរ គឺត្រូវបានបង្កើតមកសម្រាប់លេងភ្លេង សម្រាប់សរសើរនិងថ្វាយបង្គំ ។

ព្រះគម្ពីរអេសេគាល ២៨:១៣ខ

ព្រះគម្ពីរអេសាយ ១៤ហ៣១១ក,១២ក

### ៣. ឧបករណ៍ភ្លេងទាំងបីប្រភេទ គឺត្រូវបានបញ្ជូនមកទីនេះហើយ ។

ក. ឈឹង: ឧបករណ៍សម្រាប់វាយប៉ះទង្គិចគ្នា ។

ខ. ខ្លុយ: ឧបករណ៍ខ្យល់

គ. ឧបករណ៍ដែលមានខ្សែ

លូស៊ីហ្វើរ មិនបានត្រឹមតែលេងភ្លេងប៉ុណ្ណោះទេ គឺវាថែមទាំងលេខមួយផង ។ សម្លេងរបស់វា គឺជាវង់ភ្លេងដ៏ពិរោះ ដូចជាសម្លេងខ្លុយ ត្រែ និងសម្លេងផ្សេងទៀត ។ ការគ្របបាំងបល្ល័ង្ករបស់ព្រះ ដោយការចាក់ប្រេងតាំងជាចេរូប៊ីន ក៏បានលេចឡើងក្នុងការគ្របបាំងលើការសរសើរ និងការថ្វាយបង្គំ ។

លូស៊ីហ្វើរ អាចត្រូវបានទទួលនូវការអនុញ្ញាតឱ្យធ្វើជាវង់ភ្លេងទេវភាពដ៏អស្ចារ្យ ព្រមទាំងជាអ្នកចម្រៀងក្នុងការសរសើរ និងការថ្វាយបង្គំ គឺនៅតែបន្តនៅចំពោះបល្ល័ង្គ ។

ព្រះគម្ពីរយ៉ូប ៣៨:៧

ពាក្យ "កូនរបស់ព្រះ" គឺជាសេចក្ដីបញ្ជាក់ចំពោះទេវតា។ លូស៊ីហ្វើរក៏ត្រូវបានទទួលការសម្អិតសម្អាង ដោយមានត្បូងជាច្រើនបំផុត ដែលត្រូវបានថ្មែហើយ នៅពេលដែលវាបានរើចេញ និងពេលដែលដកដង្ហើម គឺវាមិនដែលមានទីបំផុតឡើយ គឺមានការផ្លាស់ប្ដូរជានិច្ច ជាទស្សនីយភាពនៃសិរីល្អនៅក្នុង

ពន្លឺពណ៌សម្បុរ និងសម្លេងនៅស្ថានសួគ៌ ។

## III. លំហនៅស្ថានសួគ៌

### ក. លូស៊ីហ្វើរបាននៅក្នុងលំហ

លូស៊ីហ្វើរដែលបានធ្លាក់ចុះពីស្ថានសួគ៌ គឺបាននៅក្នុងជង្ហុកលំហនោះឯង ។ ពេលដែលលូស៊ីហ្វើរបានបះបោរទាស់ទទឹងនឹងព្រះ ហើយក៏ត្រូវបានបណ្តេញចេញពីសស្ថានសួគ៌ "ទាំងពួកទេវតារបស់វា" គឺមួយភាគបីនៃផ្កាយ (ពួកទេវតា) ដែលនៅស្ថានសួគ៌ ដែលបានបះបោរជាមួយនឹងវា នោះក៏ត្រូវបានទម្លាក់ចុះមកដែរ ។

ព្រះគម្ពីរអេសាយ ១៤:១២

ព្រះគម្ពីរអេសេគាល២៨:១៥-១៦

ព្រះគម្ពីរវិវរណៈ ១២:៧-៩ និង ១២:៤ក

ទីលំហនោះឯង គឺត្រូវបាននៅជិតនគរស្ថានសួគ៌ក្នុងមួយរំពេចដែលលូស៊ីហ្វើរ និងពួកទេវតារស់វាត្រូវបានបណ្តេញចេញ ។

### ខ. ព្រះទ្រង់បានបំពេញទីចន្លោះ ។

ព្រះទ្រង់មានផែនការបំពេញ នូវទីលំហដែលលូស៊ីហ្វើរ និងពួកទេវតារបស់វា ត្រូវបានបណ្តេញនោះ! ព្រះទ្រង់បានបង្កើតមនុស្សមកគឺឱ្យបានទទួលនូវអំណាចគ្រប់គ្រង លើផែនដីនេះ គឺឱ្យគ្រប់គ្រងលើទាំងលូស៊ីហ្វើរ (សាតាំង) ព្រមទាំងពួកទេវតារបស់វា (ពួកវិញ្ញាណអាក្រក់) ផងដែរ ។ មនុស្សត្រូវតែបានសម្តែងខ្លួនឱ្យសាតាំងត្រូវបរាជ័យ នៅលើផែនដីនេះ ។ ព្រះទ្រង់បានបង្កើតមនុស្សមក ឱ្យបាននៅបន្ទាប់ពីព្រះអង្គ និងបានសោយរាជ្យជាមួយនឹងព្រះអង្គនៅលើបល្ល័ង្ករបស់ទ្រង់ ។ យើងជាពួកជំនុំ គឺកំពុងតែបានសម្រេចថ្វាយដល់ទ្រង់ ដូចជាទ្រង់ក៏បានប្រទាននូវ "ភាពពេញលេញ" របស់យើងដែរ ។

ទីលំហឥឡូវនេះ គឺត្រូវបានបំពេញដោយពួកជំនុំរបស់ទ្រង់នោះឯង ។

ព្រះគម្ពីរអេភេសូរ ១:២២-២៣

មនុស្សជាតិត្រូវបានបង្កើតមក សម្រាប់គោលបំណង និងមុខងារដ៏អស្ចារ្យៈ គឺឱ្យបានជាអ្នកសរសើរ និងជាអ្នកថ្វាយបង្គំដល់ព្រះនោះឯង!

ព្រះគម្ពីរអេភេសូរ ៣:២១

## IV. បំណងព្រះហឫទ័យរបស់ព្រះ

### ក.សូមឱ្យបំណងព្រះហឫទ័យទ្រង់បានសម្រេចនៅផែនដី

ព្រះយេស៊ូវទ្រង់បានបង្រៀនពួកសិស្សរបស់ទ្រង់ ឱ្យចេះអធិស្ឋានថា "សូមឱ្យបំណងព្រះហឫទ័យទ្រង់បានសម្រេចនៅផែនដី ដូចជានៅស្ថានសួគ៌ដែរ" (ម៉ាថាយ ៦:១០) ។ តើអ្វីទៅជាបំណងព្រះហឫទ័យរបស់ព្រះនៅស្ថានសួគ៌នោះ? គឺជាបំណងព្រះហឫទ័យព្រះ ដែលព្រះអង្គទ្រង់បានធ្វើសម្រេចនៅផែនដីនេះក៏ដូចជានៅស្ថានសួគ៌ដែរ ។

លោកសាវ័កយ៉ូហានក៏ត្រូវបានប្រទានឱ្យ នូវទស្សនៈដ៏ធំអស្ចារ្យ ចំពោះអ្វីដែលបានកើតឡើងនៅឯស្ថានសួគ៌សព្វថ្ងៃនេះ ហើយអ្វីដែលនឹងកើតឡើង នៅក្នុងថ្ងៃអនាគត ។ ទស្សនៈដ៏ច្រើនបណ្តាទស្សនៈ គឺរាប់បញ្ចូលទាំងករសរសើរ និងការថ្វាយបង្គំនោះឯង ។

### ខ. ការសរសើរនៅតែបន្ត

ពួកទេវតាដែលមាននៅ គឺនៅតែបន្តនូវការថ្វាយការសរសើរដល់ព្រះ ។ ព្រះគម្ពីរវិវរណៈ ៤:៨-១១ ។

**គ.ពាន់រាប់ជាពាន់**

មានទេវតាជាង១០០លាន និងស្នាព្រះហស្តដទៃទៀត កំពុងតែថ្វាយបង្គំ និងសរសើរដល់ព្រះ ។

ព្រះគម្ពីរវិវរណៈ ៥:១-១៣

**ឃ. ព្រះយេស៊ូវទ្រង់បានអធិស្ឋានថា "សូមឱ្យបំណងព្រះហឫទ័យទ្រង់បានសម្រេច នៅផែនដីដូចនៅស្ថានសួគ៌ដែរ" ។**

**១. ការថ្វាយបង្គំ**

មានទាំងការសរសើរ និងការថ្វាយបង្គំកំពុងតែបន្តនៅឯនគរស្ថានសួគ៌ក្នុងពេលឥឡូវនេះ ។ គឺជាការថ្វាយបង្គំដោយពួកទេវតារាប់ពាន់នាក់ និងការថ្វាយបង្គំដោយមនុស្សជាច្រើន ដែលមកពីគ្រប់ជនជាតិ គ្រប់កុលសម្ព័ន្ធ និងគ្រប់ភាសា កំពុងតែអរសប្បាយ (វិវរណៈ ៧:៩-១០) ។

**២. ដោយច្រៀងចម្រៀងថ្មី (វិវរណៈ ១៤:១-៣)**

**៣. ការថ្វាយបង្គំនៅពេលអនាគត**

លោកសាវ័កយ៉ូហាន បានឃើញពួកបរិសុទ្ធដែលបានរាប់បញ្ចូលទាំងពួកយើងផងដែរ ។ ការថ្វាយបង្គំព្រះ គឺបន្ទាប់ពីវិនាសកម្មរបស់សាតាំង បានចប់សព្វគ្រប់ (វិវរណៈ ១៥:២-៤) ។

យើងត្រូវតែអធិស្ឋានថា "សូមឱ្យបំណងព្រះហឫទ័យទ្រង់បានសម្រេច នៅផែនដី ដូចជានៅស្ថានសួគ៌ដែរ" ព្រះគម្ពីរវិវរណៈ ១៩:១,៣,៧ ។

ឥឡូវនេះ វាបានធ្លាក់មកលើដៃយើងហើយ យើងជាកូនក្រមុំរបស់ទ្រង់ យើងបានត្រៀមខ្លួនក្នុងការធ្វើជាអ្នកសរសើរ និងជាអ្នកថ្វាយបង្គំដល់ព្រះ ។

លោកសាវ័កយ៉ូហានក៏នៅតែបន្តថា ចូរយើងសប្បាយរីករាយ និងមានអំណរឡើង ហើយថ្វាយសិរីល្អដល់ព្រះអង្គ ចំពោះការរៀបការជាមួយនឹងកូនចៀមបានមកដល់ហើយ ហើយមហេសីរបស់ទ្រង់ក៏បានរៀបចំរួចរាល់ហើយដែរ ។ ចូរនៅតែសរសើរដល់ព្រះ តាមរយៈបបូរមាត់របស់យើង ។ យើងត្រូវតែអធិស្ឋានថា "សូមឱ្យបំណងព្រះហឫទ័យទ្រង់បានសម្រេចនៅផែនដី ដូចជានៅស្ថានសួគ៌ដែរ" ។

ព្រះគម្ពីរអេភេសូរ ១:២៣

ចូរយើងសប្បាយរីករាយ និងមានអំណរឡើង ហើយថ្វាយសិរីល្អដល់ព្រះអង្គ ។ ទ្រង់នឹងយាងមកជាឆាប់ ។ តើលោកអ្នកកំពុងតែត្រៀមខ្លួនហើយឬនៅ? តើលោកអ្នកបានស្វែងរកព្រះភក្ត្រទ្រង់ និងបង្ហាញពីសេចក្ដីស្រឡាញ់របស់លោកអ្នក ហើយឬនៅ?

ទ្រង់គឺជាអ្នកមានតម្លៃបំផុត ចំពោះការសរសើរ និងការ ថ្វាយបង្គំរបស់យើងនោះ ។

## ក្រុមពិភាក្សា

១. ចូរចែកចាយនូវពាក្យជំនិតរបស់លោកអ្នក ជាភាសាក្រិក សម្រាប់ពាក្យ "សរសើរ" ។ តើអ្វីទៅជាពាក្យជំនិតរបស់លោកអ្នក តើមានន័យយ៉ាងដូចម្ដេច?

២. ចូរពិភាក្សាពីមូលហេតុ ដែលលោកដុកទ័រ ហីល បាននិយាយថា មនុស្សជាតិត្រូវបានបង្កើតមក ។

៣. តើអ្វីទៅដែលពួកអកជឿអាចធ្វើបាន កងការបង្កើតពួកគេរួចហើយ សម្រាប់ការវិលត្រឡប់មកវិញរបស់ព្រះយេសូវ?

## ការសិក្សាដោយខ្លួនឯង

១. តើលោកអ្នកអាចបញ្ចេញសកម្មភាពបន្ថែមទៀត និងចង្អុលបង្ហាញពីការសរសើររបស់លោកអ្នក ចំពោះព្រះបានដោយវិធីណា?

២. ចូរអធិស្ឋានទូលសូមទៅព្រះ ឱ្យជួយលោកអ្នកបានច្រៀងនូវចម្រៀងថ្មី (ចម្រៀងខាងវិញ្ញាណ) កំឡុងពេលនៃការថ្វាយបង្គំរបស់លោកអ្នក ។

៣. ចូរអធិស្ឋានថា សូមព្រះទ្រង់បានបំផ្លាស់បំប្រែលោកអ្នកឱ្យចូលទៅក្នុងតំបន់កាន់តែខ្ពស់ឡើងៗ ក្នុងការសរសើរ និងថ្វាយបង្គំ ក្នុងពេលរបស់លោកអ្នកជាមួយនឹងទ្រង់ ។

# ការសរសើរ និងការថ្វាយបង្គំ

## *មេរៀនទី ៤: ការចង្អុលបង្ហាញពីការសរសើរ និងការថ្វាយបង្គំ*

### I. ការប្រគំបទភ្លេងនៅក្នុងគ្រាសញ្ញាចាស់

#### ក.ឧបករណ៍ភ្លេងដែលត្រូវប្រគំ

ឧបករណ៍ភ្លេងដែលត្រូវប្រគំ គឺត្រូវបានគេប្រើជាញឹកញាប់ ក្នុងការចង្អុលបង្ហាញនុអការសរសើរ និងការថ្វាយបង្គំតាមរយៈព្រះគម្ពីរ ។

ស្តេចដាវីឌបានដាស់តឿនក្រើនរំឭកយើង ឱ្យសរសើរដល់ព្រះ ។

ព្រះគម្ពីរទំនុកដំកើង ១៥០:៣-៥

អ្នកប្រគំបទភ្លេងដែលផ្តល់ឱ្យ នូវការសរសើរទៅតាម ឧបករណ៍ភ្លេងរបស់ពួកគេ នោះត្រូវតែស្វែងរកនូវការពិសេសៗក្នុងការធ្វើយ៉ាងដូច្នោះ ។

ព្រះគម្ពីរទំនុកដំកើង ៣៣:៣

#### ខ. ព្រះវិញ្ញាណបរិសុទ្ធ ទ្រង់បានបណ្តាលដល់ការលេងភ្លេងនោះ ។

##### ១. បញ្ចេញនូវការចាក់ប្រេងតាំង

ព្រះវិញ្ញាណបរិសុទ្ធទ្រង់អាចប្រើប្រាស់ នូវការប្រគំភ្លេងសម្រាប់ថ្វាយសិរីល្អដល់ព្រះ និងសម្រាប់ការស្តាបនាដល់ពួកបណ្តាជន ។ ការប្រគំបទភ្លេងអាចជួយបង្កើតបរិយាកាស សម្រាប់អំណោយទានជាភាសាដទៃ ការបកប្រែភាសាដទៃ ការថ្លែងទំណាយ ការប្រោសឱ្យជា ពាក្យសម្តីនៃចំណេះចេះស្ទាត់ និងប្រាជ្ញា អំណោយទាននៃសេចក្តីជំនឿ និងការធ្វើការអស្ចារ្យ ។ ព្រះគម្ពីរ ២ពង្សាវតារក្សត្រ ៣:១៥-១៦ក ។

ពួកសាសន៍យូដា គឺស្ថិតនៅកន្លែងការក្រៀមក្រោះ និងត្រូវការព្រះបន្ទូលមកពីព្រះយេហូវ៉ា ។ ដូច្នេះ ពួកគេក៏បានធ្វើដំណើរទៅជួបហោរាអេលីយ៉ា ។ ហោរាអេលីយ៉ាក៏បានទទួល ខុសត្រូវដោយការទូលសូម សម្រាប់អ្នកប្រគំបទភ្លេង ។ ការប្រគំបទភ្លេងក្នុងការសរសើរ និងថ្វាយបង្គំ គឺតែងតែផ្តល់ឱ្យជានិច្ចនូវបរិយាកាសសម្រាប់ព្រះ ក្នុងការទទួលខុសត្រូវនោះ ។

##### ២. ស្តេចដាវីឌ

ស្តេចដាវីឌ គឺនៅបន្តការច្រៀងសរសើរដល់ព្រះយេហូវ៉ា ។

ព្រះគម្ពីរទំនុកដំកើង ៧:១៧

ព្រះគម្ពីរទំនុកដំកើង ១៣:៦

ព្រះគម្ពីរទំនុកដំកើង ២១:១៣

##### ៣. ពួកសង្ឃ

ពួកលេវីចំនួន៤០០០នាក់ បានសរសើរដល់ព្រះយេហូវ៉ា ដោយមានឧបករណ៍ភ្លេង ។

ព្រះគម្ពីរ ១របាក្សត្រ ១៥:១៦

ព្រះគម្ពីរ ១របាក្សត្រ ២៣:៥

### II. ការប្រគំបទភ្លេងនៅក្នុងគ្រាសញ្ញាថ្មី

#### ក. ពួកសិស្ស

ព្រះយេស៊ូវនិងពួកសិស្សទ្រង់ បានច្រៀងចម្រៀងរួមគ្នា ។ ព្រះគម្ពីរម៉ាថាយ ២៦:៣០

## ខ. លោកសាវ័កប៉ុល

លោកសាវ័កប៉ុលក៏បានបង្រៀនដល់ពួកជំនុំ ឱ្យបានទទួលនូវចម្រៀងដែលមានការចាក់ប្រេងតាំង ។

ព្រះគម្ពីរ ១កូរិនថូស ១៤:១៥

ព្រះគម្ពីរអេភេសូរ ៥:១៩-២០

ព្រះគម្ពីរកូល៉ុស ៣:១៦

## គ. ចម្រៀងទំនុកតម្កើង

ចម្រៀងទំនុកតម្កើង គឺជាចម្រៀងសរសើរដល់ព្រះ ។

## ឃ. ចម្រៀងខាងឯវិញ្ញាណ

ចម្រៀងខាងឯវិញ្ញាណ គឺជាចម្រៀងដែលបានប្រទានឱ្យមកយើងផ្ទាល់ៗខ្លួន ដោយព្រះវិញ្ញាណបរិសុទ្ធ ព្រមទាំងជាចម្រៀងដែលច្រៀងចេញដោយឯងៗ គឺជាព្រះវិញ្ញាណដែលទ្រង់បានប្រទានឱ្យ ទាំងពាក្យសម្ដីទាំងពាក្យជូន ។

ពួកគេអាចច្រៀងនៅក្នុងភាសាចម្រៀងរៀងៗខ្លួន ឬក៏អាចច្រៀងតាមភាសាដែលគ្មានអ្នកណាដឹងក៏បានដែរ ។

## ង. កម្មបទសំខាន់ៗ

កម្មបទជាច្បងនៅក្នុងការច្រៀង គឺត្រូវតែសរសើរ និងលើកតម្កើងដល់ព្រះ ។ ពួកវាមិនមែនជាចម្រៀងដោយមានការខឹតខំប្រឹងប្រែង ឬក៏ជាការច្រៀងកម្សាន្តនោះទេ ។ បទចម្រៀងនេះក៏មិនមែនដាក់ឱ្យនៅក្នុងតំបន់មនុស្សនោះដែរ ។ គឺវាសដៅទៅឯព្រះផ្ទាល់ ដើម្បីឱ្យបានគាប់ដល់ព្រះហឫទ័យព្រះតែមួយអង្គគត់ប៉ុណ្ណោះ ។

ព្រះគម្ពីរហេព្រើរ ២:១២

## III. ការចង្អុលបង្ហាញពីការសរសើរ

## ក. ខាងឯវិញ្ញាណ

**១. ការសរសើព្រះជាមួយនឹងសម្លេង**

ព្រះគម្ពីរ ១របាក្សត្រ ១៦:៩

ព្រះគម្ពីរទំនុកដំកើង ៧១:២៣-២៤ក

**២. តូវបង្កើតឱ្យបានជានិស្ស័យក្នុងការជំជែកជាមួយព្រះ ។**

**៣. ត្រូវសរសើរពីការងារដ៏អស្ចារ្យរបស់ទ្រង់ ។**

**៤. ការរស់នៅដោយការនិយាយប្រចាំថ្ងៃ គឺក្នុងសរសើរដល់ទ្រង់ ។**

**៥. ចូរសរសើរព្រះអង្គដោយការនិយាយ និងការច្រៀង ។**

**៦. ចូរបណ្ដុះនូវទម្លាប់នៃការសរសើរ ។**

ព្រះគម្ពីរ ១របាក្សត្រ១៦:៩

ព្រះគម្ពីរទំនុកដំកើង ៤០:១៦

យើងលើកតម្កើងដល់ព្រះយេហូវ៉ា កាន់ច្រើនប៉ុណ្ណា នោះទ្រង់ក៏បានត្រឡប់មកនៅក្នុងភ្នែករបស់យើង កាន់តែធំ ហើយបញ្ហារបស់យើងក៏កាន់តែតូចទៅៗ នៅក្នុងភ្នែករបស់យើងយ៉ាងដូច្នោះដែរ ។

ព្រះគម្ពីរទំនុកដំកើង ៦៦:៨

ការសរសើរដល់ព្រះអម្ចាស់ គឺអាចនៅជាមួយនឹងបទចម្រៀង គឺជាការចង្អុលបង្ហាញ នូវអារម្មណ៍នៃការពេញដោយសេចក្ដីអំណរ គឺបានមកដោយឯងៗ ។ វាក៏អាចកើតបាននូវអ្វីដែលយើងនិយាយនោះដែរ ។ ការសរសើរ គឺជាការចង្អុលបង្ហាញពីតួនាទី អារម្មណ៍ នៃការប្រោសឱ្យជា ដែលអាច

បំពេញការងារដោយមានកម្លាំង ក្នុងការរស់នៅរបស់យើងទាំងស្រុងនោះដែរ ។

### ៧. ការស្រែកច្រៀងទៅកាន់ព្រះ

មានពេលវេលាមួយដើម្បីនិយាយ ក៏មានពេលវេលាមួយ ទៀតដើម្បីស្រែកច្រៀងដែរ ។

ព្រះគម្ពីរទំនុកដំកើង ៤៧:១

ព្រះគម្ពីរអេសាយ ១២:៦

ព្រះគម្ពីរ ១សាំយូអែល ៤:៥

ហឹបដែលបានត្រូវគេចាប់បាន ឥឡូវនេះបានវិលត្រឡប់មកវិញហើយ ពួកគេក៏បានស្រែកច្រៀងពីជ័យជម្នះដ៏បរិបូរណ៍ ។

ព្រះគម្ពីរលូកា ១៩:៣៧

## ខ. ខាងផ្នែករូបកាយ

### ១. ការឈរនៅ

ការឈរនៅគឺជាចម្រៀងមួយ ពេញដោយក្តីសង្ឃឹម ។

ព្រះគម្ពីរ ២របាក្សត្រ ២០:១៩

ព្រះគម្ពីរវិវរណៈ ៧:៩-១០

ព្រះគម្ពីរទំនុកដំកើង ៣៣:៨

ព្រះគម្ពីរទំនុកដំកើង ១៣៥:១-២

### ២. ការទះដៃ

ការទះដៃរបស់លោកអ្នក គឺជាការចង្អុលបង្ហាញនូវភាពអរសប្បាយ សេចក្តីអំណរ និងការព្រមព្រៀង ។

ព្រះគម្ពីរទំនុកដំកើង ៤៧:១

ព្រះគម្ពីរអេសាយ ៥៥:១២

### ៣. ការដើរដង្ហែរ

ការដើរដង្ហែរ គឺជាការចង្អុលបង្ហាញពីជ័យជម្នះខាងរូបកាយ ។ ការដើរដង្ហែរជុំវិញទីក្រុងយេរីខូរការបញ្ជារនោះ គឺបាននាំមកនូវជ័យជម្នះដ៏ពេញលេញ ។ ព្រះគម្ពីរយ៉ូស្វេ ៦:២-៥ ។

កូនក្រមុំរបស់ព្រះគ្រីស្ទ គឺត្រូវបានបង្ហាញរូបភាពពីកងទ័ព ដែលបានដើរដង្ហែរទាំងអស់គ្នានោះឯង ។

ព្រះគម្ពីរបទចំរៀងសាឡូម៉ូន ៦:៤,១០

### ៤. ការលោតរាំ

ការលោតរាំគឺជាការបើកសម្តែងបង្ហាញ ពីការសរសើរខាងផ្នែករូបកាយដ៏ច្រើនលើសលុបនោះឯង ។ គឺវាតម្រូវឱ្យប្រើប្រាស់ខាងផ្នែករូបកាយទាំងស្រុង ។ វាជាការចូលរួមយ៉ាងពេញលេញ និងជាការបញ្ចេញទាំងស្រុងនូវការហាមឃាត់របស់យើង ឱ្យមានស្មារតីដឹងខ្លួន នៅពេលដែលយើងបានស្តាប់បង្គាប់ដល់ព្រះ ហើយនិងបានរាំនៅចំពោះទ្រង់ ដោយនូវឥទ្ធិឫទ្ធិរបស់យើងនោះឯង ។

ព្រះគម្ពីរទំនុកដំកើង ១៤៩:៣

ព្រះគម្ពីរ ២សាំយូអែល ៦:១៤

យើងនឹងសិក្សាបន្ថែមទៀតអំពីការរាំ នៅខាងចុងនៃមេរៀននេះ ។

### ៥. ការស្រែកច្រៀង

មានការចង្អុលបង្ហាញ ពីសេចក្តីអំណររបៀបនេះ នៅក្នុងព្រះអម្ចាស់ដែលមានតែផ្លូវមួយទេ

ដើម្បីបង្ហាញថា ទាល់តែតាមរយៈការស្រែកច្រៀងនេះ ។ រីឯការប្រោសឱ្យជា និងការរំដោះដ៏អស្ចារ្យ ដែលតែងតែចូលមក កំឡុងពេលនៃការសើចដ៏បរិសុទ្ធនៅចំពោះព្រះអម្ចាស់ ។ ការសើចដ៏ពិត គឺជាការបើកសម្ដែង នូវសេចក្ដីអំណរផ្នែកខាងក្នុង ។

ព្រះគម្ពីរទំនុកដំកើង ១២៦:២

ព្រះគម្ពីរយ៉ូប ៨:២០-២១

ព្រះគម្ពីរនេហេមា ៨:១០ខ

IV. **ការចង្អុលបង្ហាញពីការថ្វាយបង្គំ**

**ក.ការចង្អុលបង្ហាញខាងផ្នែករូបកាយ**

**១. ការលើកដៃឡើង**

នៅក្នុងតំបន់ផ្នែកធម្មជាតិ ការលើកដៃលោកអ្នកឡើង គឺជាទីសម្គាល់ពីការចុះចូល ។ នៅក្នុងការថ្វាយបង្គំ វាគឺជាទីសម្គាល់នៃយញ្ញបូជា និងការចុះចូល ។

ព្រះគម្ពីររ៉ូម ១២:១

ព្រះគម្ពីរទំនុកដំកើង ១៤១:២

វាគឺជាការឈោងចាប់ ដោយការស្រែកឃ្លាននៅចំពោះព្រះ ។

ព្រះគម្ពីរទំនុកដំកើង ១៤៣:៦

ព្រះគម្ពីរទំនុកដំកើង ៤២:១-២

ការលើកដៃលោកអ្នកឡើង ក៏អាចបានទទួលព្រះពរមកពីព្រះដែរ ។

ព្រះគម្ពីរទំនុកដំកើង ១៤៣:២

ព្រះគម្ពីរទំនុកដំកើង ៦៣:៤

ការលើកដៃរបស់លោកអ្នកឡើង គឺជាអាចជាការចង្អុលបង្ហាញ នូវសេចក្ដីអធិស្ឋាន និងការបួងសួងខាងផ្នែករូបកាយ ។

ព្រះគម្ពីរទំនុកដំកើង ២៨:២

ព្រះគម្ពីរ ១ធីម៉ូថេ ២:៨

**២. ការក្រាបចុះ ឬការលុតជង្គង់ចុះ**

ការក្រាបចុះ ឬការលុតជង្គង់ចុះ គឺជាឥរិយាបថនៃការគោរពយ៉ាងជ្រាលជ្រៅ និងការសង្ឃឹម ។

ព្រះគម្ពីរទំនុកដំកើង ៩៥:៦

**៣. ការផ្ទាក់ចុះនូវការក្រាបថ្វាយបង្គំ**

ការក្រាបផ្កាប់មុខចុះទៅលើកម្រាល គឺជាការចង្អុលបង្ហាញនូវការសង្ឃឹម និងការថ្វាយបង្គំដ៏ជ្រៅបំផុត ក្នុងការគោរពដ៏ជ្រាលជ្រៅ និងការបន្ទាបខ្លួនដ៏ពិត ។

ព្រះគម្ពីរ ១ពង្សាវតារក្សត្រ ១៨:៣៩

ព្រះគម្ពីរ ១របាក្សត្រ ២៩:២០

**៤. ការស្ងប់ស្ងាត់**

ការស្ងប់ស្ងាត់អាចត្រូវបានចង្អុលបង្ហាញ ពីការថ្វាយបង្គំ ។

ព្រះគម្ពីរសាស្តា ៣:៧

ព្រះគម្ពីរទំនុកដំកើង ៤៦:១០

**៥. ការស្រក់ទឹកភ្នែក**

ការស្រក់ទឹកភ្នែក គឺតែងតែត្រូវបានទទួលខុសត្រូវចំពោះ ការចង្អុលបង្ហាញ នូវសេចក្ដីស្រឡាញ់ និងសេចក្ដីមេត្តាករុណារបស់ព្រះ ដ៏មានប្រពលភាពនោះឯង ។ ព្រះគម្ពីរកិច្ចការ ២០:៣៦-៣៧ ។

ការទទួលខុសត្រូវ ក្នុងការសរសើរដោយស្រក់ទឹកភ្នែក នោះគឺជាការចង្អុលបង្ហាញ ទៅលើការដឹងគុណ និងការគោរពបូជាដ៏លើសលុបនោះឯង ។ ពួកគេ គឺតែងតែនាំមកនូវការរំដោះផ្នែកខាងអារម្មណ៍ និងខាងការប្រោសឱ្យជាផ្នែកខាងក្នុង ដ៏មានជម្រៅជ្រៅនោះ ។

ព្រះគម្ពីរលូកា ៧:៣៧-៣៨

ការស្រក់ទឹកភ្នែក គឺតែងតែដើរមុនសេចក្ដីអំណរ និងការជោគជ័យដ៏ធំឧត្ដមនោះឯង ។

ព្រះគម្ពីរទំនុកដំកើង ១២៦:៥-៦

## ខ. ការលោតរាំ

ការលោតរាំគឺមិនមែនជាការសំខាន់ជាជាង ការចង្អុលបង្ហាញដទៃទៀតនៃការសរសើរនោះទេ ។ ទោះជាយ៉ាងណាក៏ដោយ ក៏វាបានបន្ថែមនូវវាទប្បដិវាទ និងសេចក្ដីត្រូវការពីការពន្យល់បន្ថែមទៀត ជាជាងទម្រង់ដទៃទៀតយ៉ាងដូច្នោះនោះដែរ ។

ការលោតរាំគឺជាការសម្ដែងដ៏ខ្ពស់បំផុត ។ វាតម្រូវឱ្យមានការប្រើប្រាស់ទៅលើរូបកាយទាំងស្រុង ជាលំដាប់លំដោយក្នុងការបង្ហាញពីសេចក្ដីអំណរ ក្នុងការសរសើរ និងការថ្វាយបង្គំនៅចំពោះព្រះអម្ចាស់ ។

ពាក្យជាភាសាហេព្រើរ និងភាសាក្រិកគឺបានបកប្រែថា "រាំ" មានន័យថា "លោតផ្លោះ លោតហក់ លើកជើង លោតកញ្ឆេង" ។ ពាក្យជាលំដាប់លំដោយទៅទៀត វាគឺជាការទៅដោយឯកឯង និងមិនមែនជាបង្រៀនខាងផ្នែកធម្មជាតិនោះ ។

ព្រះគម្ពីរកិច្ចការ ៣:៨ និង ទំនុកដំកើង ១៤៩:៣

### ១. នៅក្នុងពិធីបុណ្យ

ពួកកូនចៅអ៊ីស្រាអែល បានរាំនៅក្នុងពិធីបុណ្យនៃសេចក្ដីសង្គ្រោះ និងការរំដោះ គឺនៅពេលដែលពួកគេត្រូវបានរំដោះចេញពីស្រុកអេស៊ីព្ទមក ។

ព្រះគម្ពីរនិក្ខមនំ ១៥:២០

ពួកគេមានសេចក្ដីអំណរនៅពេល ដែលហឹបនៃសេចក្ដីសញ្ញាត្រូវបានកែជាថ្មីឡើងវិញ ។

ព្រះគម្ពីរ ២សាំយូអែល ១៦:១៤

### ២. ការរាំខាងឯវិញ្ញាណ

ការរាំខាងឯវិញ្ញាណ គឺជាការចេញមកដោយឯង។ ជាដំបូង គឺមិនមែនមកពីចំណែកខាងរូបកាយនោះទេ ហើយក៏អាចបានទទួលនូវការចង្អុលបង្ហាញនូវការលោតកញ្ឆេង ការបង្វិលខ្លួន ការលោតហក់ និងការលោតផ្លោះជាដើម ។ ជួនកាលវាត្រូវបានទទួលស្គាល់ដោយបទភ្លេង ដែលមកពីគ្រឿងឧបករណ៍ភ្លេង និងអ្នកចម្រៀងមកដែរ ។

ព្រះគម្ពីរទំនុកដំកើង ១៤៩:៣

### ៣. ជាលក្ខណៈបុគ្គល ឬជាក្រុម

ស្ដេចដាវីឌបានរាំនៅចំពោះយេហូវ៉ា ។ នាងម៉ារាម និងស្ត្រីឯទៀតក៏បានរាំ ។ ការរាំខាងឯវិញ្ញាណ គឺមិនមែនជាការាំ ដែលមានសមាជិកភេទផ្ទុយគ្នានោះទេ ។

មនុស្សទាំងក្មេងទាំងចាស់ក៏បានរាំទាំងអស់គ្នា ។

ព្រះគម្ពីរយេរេមា ៣១:១៣ក

### ៤. គ្មានកំណត់អាយុ

គ្មានការកំណត់អាយុ ចំពោះការរាំខាងឯ

វិញ្ញាណនោះទេ ។ ចូរចំណាំនូវពាក្យនេះ "មនុស្ស ទាំងក្មេងទាំងចាស់" ។

## ៥. ការច្រៀងនិងការរាំ

ការច្រៀងនិងការរាំ គឺតែងតែទៅទាំងអស់គ្នា។

ព្រះគម្ពីរ ១សាំយូអែល ២៩:៥

## ៦. ពេលវេលាដែលត្រូវរាំ

មានពេលវេលាដ៏ត្រឹមត្រូវ ដែលត្រូវរាំ ។

ព្រះគម្ពីរសាស្តា ៣:៤

## ៧. ការរាំនៅចំពោះព្រះអម្ចាស់

នេះគឺជាការចង្អុលបង្ហាញ នូវការសរសើរ គឺជាការស្តាប់បង្គាប់ នូវការបើកសម្តែងមកពីព្រះបន្ទូលតែមួយអង្គប៉ុណ្ណោះ ដែលយើងត្រូវតែសរសើរព្រះអង្គដោយការរាំ ។ នេះគឺជាសកម្មភាពនៃឆន្ទៈរបស់យើងមានអារម្មណ៍ឆោតល្ងង់ យ៉ាងដូច្នោះ គឺដោយសារតែយើងមានការស្តាបបង្គាប់ព្រះ និងមានសេចក្តីអំណរជមួយនឹងពួកអ្នកជឿដទៃទៀត ដែលពួកគេបានរាំនៅចំពោះព្រះអម្ចាស់នោះ ។

## ៨. ការរាំដោយនូវព្រះវិញ្ញាណ

ការរាំដោយនូវព្រះវិញ្ញាណ គឺនៅពេលដែលរូបកាយទាំងមូលរបស់យើង បាននៅក្រោមការដឹកនាំទាំងស្រុង របស់ព្រះវិញ្ញាណបរិសុទ្ធនោះឯង ។ ពួកអ្នកជឿនៅ កំឡុងពេលនេះ គឺបានទទួលនូវ "ការស្រាយ" យ៉ាងពេញលេញដោយព្រះវិញ្ញាណ និងដោយការជ្រួតជ្រាបទាំងស្រុង ដោយនូវអំណាចចេស្តារបស់ទ្រង់ ដែលពួកគេមិនបានដឹងខ្លួនទាំងស្រុងចំពោះអស់អ្នក ដែលនៅជុំវិញខ្លួននោះ ។ វាតែងតែបាននៅក្នុងពេល ដ៏គ្រប់លក្ខណ៍របស់ព្រះ គឺដែលយើងមិនធ្វើឱ្យខូច ពេលវេលានោះទេ ដើម្បីឱ្យបានស៊ីសង្វាក់ដ៏គ្រប់ លក្ខណ៍ដែលបង្ហូរមកជាមួយនឹងការបំផ្លាស់បំប្រែរបស់ព្រះ នៅក្នុងពេលភ្លាមៗនោះ ។

## ៩. ការកែជាថ្មីឡើងវិញ នូវការថ្លែងទំនាយ

ការកែជាថ្មីឡើងវិញចំពោះការរាំ គឺត្រូវបានទទួលនូវការ ថ្លែងទំនាយ ។

ព្រះគម្ពីរយេរេមា ៣១:៤,១៣

## ក្រុមពិភាក្សា

១. តើយើងអាចសិក្សារៀនសូត្រ ពីទម្លាប់នៃការសរសើរដោយរបៀបណា?

២. ការរាំគឺជាការបើកសម្តែងដ៏ខ្ពស់បំផុត នៃការចង្អុលបង្ហាញនូវការសរសើរខាងឯផ្នែករូបកាយ ។ ចូរពិភាក្សាពីរបៀបចូលរួមឱ្យបានពេញលេញ និងឱ្យមានការរំដោះទាំងស្រុងចំពោះការរារាំង និងការដឹងខ្លួនផ្ទាល់របស់យើង ។

៣. ហេតុអ្វីបានជាការស្រក់ទឹកភ្នែក តែងតែមានការដើរមុននូវសេចក្តីអំណរ និងជ័យជម្នះដ៏ធំឧត្តមនោះ?

## ការសិក្សាដោយខ្លួនឯង

១. តើប្រយោគជាបន្តបន្ទាប់នេះ មានន័យយ៉ាងដូចម្តេចចំពោះលោកអ្នក: "ការសរសើរគឺជាការចង្អុលបង្ហាញ ពីការប្រោសឱ្យជា ទៅលើអារម្មណ៍ជាវិជ្ជមាន ដែលយើងអាចបំពេញការងារដោយមានកម្លាំង និងបានជាប់លាប់នៅនោះ?"

២. តើការស្ងប់ស្ងាត់គឺជាការចង្អុលបង្ហាញ ទៅលើការថ្វាយបង្គំដោយរបៀបណា?

៣. តើការរាំគឺបានមកពីការសរសើរ និងការថ្វាយបង្គំ មែនឬទេ គឺទាំងការមានវាទប្បដិវាទសម្រាប់លោកអ្នកនោះ?

ក. ប្រសិនបើដូច្នោះមែន តើមកពីមូលហេតុអ្វី? តើការបង្រៀនដូចម្តេច ដែលអនុញ្ញាតឱ្យមានវាទប្បដិវាទនោះ?

ខ. តើលោកអ្នកមានអារម្មណ៍ដូចម្តេចដែរ បន្ទាប់ពីការសិក្សាមេរៀននេះ? តើលោកអ្នកបានរំឮកពីការផ្លាស់ប្រែរបស់លោកអ្នក ពីគ្រប់ការទាំងអស់ដែរឬទេ?

# ការសរសើរ និងការថ្វាយបង្គំ

## *មេរៀនទី ៥: ជ័យជម្នះតាមរយៈការសរសើរ និងការថ្វាយបង្គំ*

### I. ការថ្វាយបង្គំដោយវិញ្ញាណ

### ក.ព្រះរាជបញ្ញារបស់ព្រះយេស៊ូវ

ព្រះគម្ពីរយ៉ូហាន ៤:២៤

យើងអាចសរសើរព្រះដោយអស់ពីចិត្ត អស់ពីព្រលឹង និងអស់ពីរូបកាយរបស់យើង ។ ប៉ុន្តែ យើងអាចត្រឹមតែថ្វាយបង្គំព្រះអង្គដោយវិញ្ញាណតែប៉ុណ្ណោះ ។ រឿងដ៏អស្ចារ្យបំផុតនោះ គឺនៅក្នុងជីវិតត្រូវតែថ្វាយបង្គំដល់ព្រះអម្ចាស់ ជាព្រះនៃយើងនោះឯង ។

### ខ. ការសរសើរ និងថ្វាយបង្គំជាបន្ត

យើងបានចូលមកតាមទ្វារព្រះអង្គ ដោយអរព្រះគុណ ។ យើងបានចូលមកឯទីលានរបស់ទ្រង់ ដោយការសរសើរ និងអរព្រះគុណពេញនៅក្នុងដួងចិត្តរបស់យើង ។ យើងសរសើរដល់ព្រះអម្ចាស់ពេញដោយសម្លេងរបស់យើង ។ យើងទះដៃរបស់យើង ។ យើងរាំនៅចំពោះព្រះអម្ចាស់ ។

ព្រះគម្ពីរទំនុកដំកើង ១០០:៤

ក្នុងមួយរំពេចដែលភ្លេងបានបន្ថយល្បឿន នោះព្រះវិញ្ញាណបរិសុទ្ធបាននាំយើង ឱ្យចូលទៅក្នុងការថ្វាយបង្គំ ។ តើជាបន្តបន្ទាប់ទៅទៀតនោះមានអ្វីនៅក្នុងទីលាន ដែលអាចមិនសមរម្យនៅលើបល្ល័ង្កនៃព្រះនោះ ។ យើងឈរដោយមានស្មារតី ។ យើងលើកដៃរបស់យើងឡើង ។ យើងអាចលុតជង្គង់ចុះនៅចំពោះទ្រង់ ។ យើងអាចក្រាបចុះ ។ យើងថ្វាយបង្គំទ្រង់ ដោយអស់ពីចិត្តរបស់យើង ។ យើងសម្លឹងមើលព្រះភក្ត្ររបស់ទ្រង់ ដែលមានពេញដោយសម្រស់ស្រស់ស្អាត គឺដែលទ្រង់បានញញឹមមកកាន់ខ្ញុំ ។ ទ្រង់បានហ៊ុំព័ទ្ធការពារ និងបាននាំខ្ញុំឱ្យចូលទៅក្នុងទីលាន ។ ភាពរឹងនៃចិត្តក៏ត្រូវបានបំបាក់បំបែក ។ នៅពេលដែលទ្រង់បានឱបរិតយើង គឺធ្វើឱ្យចិត្តយើងទន់ដូចជាសាច់ដើម្បីឱ្យបានច្របាច់ចូលទៅក្នុងពុម្ពរបស់ព្រះអង្គទ្រង់ ។ យើងក៏ត្រូវបានបំផ្លាស់បំប្រែពីសិរីល្អទៅដល់សិរីល្អ ។

សព្វថ្ងៃនេះយើងអាចចូលមកដល់ បល្ល័ង្កនៃព្រះគុណដោយក្លាហាន ។

ព្រះគម្ពីរហេព្រើរ ៤:១៦

### គ. ថ្ងៃនៃការទទួលទណ្ឌកម្មលាងកំហុស

ដូចជាសម្តេចសង្ឃនៅថ្ងៃ នៃការទទួលទណ្ឌកម្មលាងកំហុស នោះយើងបានរើចូលទៅក្នុងវាំងនន ។ វាំងននគឺបានត្រូវពុះញែកដាច់ចេញពីគ្នាហើយ ។ នេះគឺជាការដែលគួរឱ្យភ័យខ្លាច ក្នុងពេលមួយរំពេចភ្លាមៗនេះ ។ នៅថ្ងៃនៃការទទួលទណ្ឌកម្មលាងកំហុស នោះសម្តេចសង្ឃបានឈរនៅក្នុងទីបរិសុទ្ធរួចជាស្រេចហើយ ដើម្បីចូលទៅខាងក្នុងនៃវាំងនន ។ អំពើបាបរបស់ពួកបណ្តាជន ក៏ត្រូវបានរើចេញនឹងត្រូវធ្លាក់ទៅលើអ្នករងជំនួសមួយទៀត ហើយក៏បញ្ជូនចេញទៅឯទីរហោស្ថាន ។ រីឯកូនចៀមដែលឥតខ្ចោះ (មិនមានទោស) ក៏ត្រូវបានទៅជាអ្នករងជំនួសវិញ ។ គាត់មានស្លឹកឈើនៅក្នុងដៃ ហើយក៏បានជ្រលក់ចូលទៅក្នុងចានក្លាំដាក់ឈាមនោះ ក៏រលាស់ទៅលើទីបរិសុទ្ធបំផុត លើទីសន្តោសប្រោសនោះ ។ ស្លឹកឈើនោះគឺជារុក្ខជាតិដ៏តូច គឺជាផលកម្មនៃបណ្តាសា មាន

តែព្រះយេស៊ូវមួយអង្គទេ ដែលជាអ្នកទទួលយកបណ្តាសានោះដាក់នៅលើរូបអង្គទ្រង់ ។ ទ្រង់ក៏ជាដង្វាយដែលយកចេញមកពីអាសនា និងពីសេចក្តីក្រោតទាំងអស់គឺនៅក្នុងព្រះហស្តរបស់ទ្រង់ហើយ ។

វាំងនននោះក្រាសណាស់ ដែលលាតសន្ធឹងពីជញ្ជាំងម្ខាងទៅជញ្ជាំងម្ខាង ចាប់ពីកម្រាលឡើងទៅដល់ពិដាន ។ គ្មានផ្លូវណាចូលទៅខាងក្នុងបានឡើយ ទោះជាខាងលើខាងក្រោមនៅជុំវិញ ។ ក៏គ្មានទ្វារចូលទៅដែរ ។

## ឃ. វាំងនននោះត្រូវបានបកចេញ ហើយចូលទៅខាងក្នុង

អ្នកនិពន្ធព្រះគម្ពីរហេព្រើរ បានបញ្ជាក់ពីការនេះហើយ ។

ព្រះគម្ពីរហេព្រើរ ៩:៨

នៅពេលដែលសង្ឃចូលទៅខាងក្នុងវាំងនននោះ គឺគាត់បានចូលដោយនូវតំបន់ខាងឯវិញ្ញាណតែប៉ុណ្ណោះ ។ គាត់ចូលមកថ្វាយបង្គំ "ដោយវិញ្ញាណនិងសេចក្តីពិត" ។ តើវាអាចបានជាយ៉ាងដូច្នោះឬទេ ដែលសម្តេចសង្ឃអាចបើកចូលទៅខាងក្នុងវាំងនន ខាងឯវិញ្ញាណនោះបាន ដូចជាលោកភីលីពបានបកស្រាយ ដោយព្រះវិញ្ញាណដែលចេញមកពីទីក គឺជាកន្លែងដែលគាត់ទើបនឹងបានជ្រមុជឱ្យដល់អ្នកកម្រៀវ ពីស្រុកអេធីយ៉ូពី ដែលនៅឆ្ងាយពីទីក្រុងអាសូតទៅនោះឬ?

ដែលយើងត្រូវបានរំដោះច្រើនប៉ុណ្ណា នោះយើងក៏ត្រូវសម្អាត និងអាចបានទទួលនូវការចូលមកដោយអង់អាចនៅចំពោះបល្ល័ង្កនៃព្រះបានច្រើនប៉ុណ្ណោះដែរ ។ ព្រះវិញ្ញាណបានលើកយើងឡើង និងនាំយើងចូលទៅខាងក្នុងនៃវាំងនននោះ ។ នៅទីនោះយើងបានថ្វាយបង្គំព្រះដោយនូវវិញ្ញាណ និងសេចក្តីពិត ដូចជាព្រះយេស៊ូវទ្រង់បានមានបន្ទូលទុកហើយនោះឯង ។ យើងក៏អាចចូលមកនៅចំពោះបល្ល័ង្កនៃព្រះនោះទៅក្នុងព្រះវត្តមាននៃព្រះ ដោយអង់អាចបានដែរ ។

ព្រះគម្ពីរទំនុកដំកើង ៤២:១

ដើម្បីចូលទៅក្នុងការថ្វាយបង្គំដ៏ពិត នោះយើងនឹងត្រូវតែបានរើចូលទៅតំបន់ខាងឯវិញ្ញាណនោះឯង ។ ព្រះទ្រង់ជាវិញ្ញាណ ហើយព្រះយេស៊ូវទ្រង់មានបន្ទូលថា អស់អ្នកណាដែលថ្វាយបង្គំទ្រង់ គឺត្រូវតែថ្វាយបង្គំដោយវិញ្ញាណនោះឯង ។

## ង. ការមុជចូលទៅក្នុងព្រះវត្តមានរបស់ព្រះអង្គ ។

ព្រះគម្ពីរទំនុកដំកើង ១០៥:៤

ពេលដែលយើង ចូលទៅក្នុងព្រះវត្តមានរបស់ព្រះអង្គនោះចិត្តរបស់យើងនិយាយជាមួយនឹងស្តេចដាវីឌថា "ខ្ញុំចង់ស្វែងរកព្រះភក្ត្រទ្រង់" ។ តើយើងត្រូវស្វែងរកព្រះហស្តរបស់ព្រះញឹកញាប់ដោយរបៀបណា បើការសម្រេចចិត្តដែលជាការសម្រេចចិត្តខាងឯសាច់ឈាមរបស់យើង នោះត្រូវបានសម្រេចទៅហើយនោះ? វាមិនមែនសម្រាប់យើងទេ ។ វាគឺសម្រាប់ព្រះ ។

មានពេលវេលាជាច្រើន ដែលយើងបានចូលមកក្នុងព្រះវត្តមានដ៏មានច្រើនលើសលុបរបស់ព្រះអង្គ គឺកំឡុងពេលយើងបានរួមគ្នាថ្វាយបង្គំនោះ ។ ការមានអារម្មណ៍ចំពោះការចាក់ប្រេងតាំងរបស់ព្រះ និងមិនមានការទទួលស្គាល់ ចំពោះការចាក់ប្រេងតាំងក្នុងថ្វាយបង្គំទាំងទុក្ខព្រួយនេះ មានអ្នកខ្លះមានការបាត់បង់នូវការយល់ដឹងថា នេះគឺជាទីសម្គាល់ ដែលបានប្រទានឱ្យនូវការនិយាយភាសាដទៃ មានការបកប្រែភាសាដទៃ ឬក៏មានការថ្លែងទំនាយជាដើម ។ ក្នុងពេលភ្លាមៗនោះ ការចាក់ប្រេងតាំងដ៏ពេញកម្លាំងក៏បានចាកចេញទៅ

ហើយ ក៏មានមនុស្សត្រូវគេសុំកន្លែងអង្គុយ ហើយយើងក៏បានចេញទៅ "នៅជាប់នឹងកម្មវិធី" ។ ព្រះវរបិតានៃយើង ដែលគង់នៅស្ថានសួគ៌ គឺទ្រង់បានចាកចេញទៅគង់នៅតែមួយអង្គឯងវិញ ។ តើទ្រង់បានចំណាយពេលយូរប៉ុណ្ណាសម្រាប់យើងដើម្បីចូលមកនិងចំណាយពេលជាមួយនឹងទ្រង់វិញ ។ យើងត្រូវការសិក្សា ពីការលង់ចូលទៅក្នុងព្រះវត្តមានរបស់ទ្រង់ ហើយថ្វាយបង្គំរហូតសិរីល្អបានចូលមក ។

ព្រះគម្ពីរអេសាយ ៦០:១

## ច. ត្រូវបានអនុលោមទៅតាមរូបភាពរបស់ទ្រង់

នៅក្នុងទីលាន គឺនៅពេលដែលយើងកំពុងតែរាំនៅចំពោះព្រះអម្ចាស់អស់ពីលទ្ធភាពរបស់យើង ដើម្បីឱ្យបានចូលមកក្នុងព្រះវិញ្ញាណ ។ ចំពោះទំនៀមទម្លាប់ខាងសាសនា និងភាពមិនរស់រាយខាងឯវិញ្ញាណ នោះនឹងត្រូវដកចេញ ។ រីឯសំណល់នៃចិត្តរបស់យើង គឺដូចជាដីឥដ្ឋដែលនៅក្នុងដៃរបស់ជាងប្រមោក គឺគេអាចធ្វើឱ្យទន់និងធ្វើឱ្យរឹងនៅចំពោះព្រះ ។

កំឡុងពេលនៃការថ្វាយបង្គំអស់រយៈពេលវែង និងកាន់តែជិតស្និទ្ធ គឺដូចជាទ្រង់ជួយទប់ជ្រងយើងឱ្យចូលកាន់តែជិតព្រះអង្គ ដូចជាដីឥដ្ឋដែលបានច្របាច់ឱ្យទន់ដោយការលុញសូន នោះយើងក៏កាន់តែអនុលោមទៅតាមរូបភាពរបស់ព្រះអង្គ ។

ព្រះគម្ពីររ៉ូម ៨:២៩

ព្រះគម្ពីរ ២កូរិនថូស ៣:១៨

## ឆ. មនុស្សជាតិត្រូវបានបង្កើតមក ឱ្យមានរូបភាពដូចព្រះ ហើយឱ្យបានស្លៀកពាក់ដោយនូវសិរីល្អរបស់ទ្រង់ ។

ប៉ុន្តែ មនុស្សជាតិបានធ្វើបាប ក៏បានធ្លាក់ចុះនូវសិរីល្អនោះ ហើយក៏គ្មានសម្លៀកបំពាក់នៃសិរីល្អរបស់ព្រះ នោះតទៅទៀតឡើយ ។ យើងមិនអាចមានការអស់ទាំងនោះ ដែលទ្រង់បានបង្កើតយើងមក រហូតដល់សិរីល្អនោះត្រូវបានកែជាថ្មីឡើងវិញ ។

ព្រះគម្ពីររ៉ូម ៣:២៣

## II. ការសាងសង់អាសនាសម្រាប់ថ្វាយបង្គំ

ការសាងសង់អាសនាជាលក្ខណៈឯកជន ឬជាលក្ខណៈក្រុមជាបន្តៗតាមរយៈព្រះគម្ពីរសញ្ញាចាស់ គឺជាការសាងសង់អាសនានៃការសរសើរ សម្រាប់អ្វីដែលព្រះទ្រង់បានធ្វើរួចមកហើយ ។ ពាក្យជាភាសាហេព្រើរសម្រាប់អាសនានេះ មានន័យថា "កន្លែងថ្វាយយញ្ញបូជា" ។

ព្រះទ្រង់នៅតែមានព្រះបន្ទូល ទៅពួកបណ្តាជនរបស់ព្រះអង្គអំពីការសាងសង់អាសនាខាងឯវិញ្ញាណ ។ យើងធ្វើដូច្នេះគឺដោយការយាងមករបស់ទ្រង់តែមួយអង្គគត់ ឬក៏នៅក្នុងក្រុម មកធ្វើជាដង្វាយយញ្ញបូជា តាមរយៈការសរសើរ និងការថ្វាយបង្គំនោះឯង ។

គ្រប់ទីកន្លែងដែលលោកអ័ប្រាហាំ លោកអ៊ីសាក និងលោកយ៉ាកុបបានធ្វើដំណើរទៅ នោះពួកគេបានសាងសង់អាសនានៃការថ្វាយបង្គំនោះឯង ។ អាសនាគឺជាទីកន្លែងថ្វាយយញ្ញបូជា ។ លោកអ័ប្រាហាំគឺជាមិត្តភក្តិរបស់ព្រះ ។ ជាច្រើនដង ដែលព្រះគម្ពីរបានបើកសម្តែងដើរតាមក្នុងការសាងសង់អាសនានោះ ក៏មានការបង្ហាញខ្លួនរបស់ពួកទេវតា ឬក៏ការលេចមករបស់ព្រះអង្គទ្រង់ នៅកន្លែងដែលគាត់ធ្វើធ្វើអាសនានោះ ។

នៅពេលដែលយើងថ្វាយបង្គំព្រះដោយវិញ្ញាណ និងសេចក្តីពិត នោះយើងក៏បានសង់អាសនាខាងឯវិញ្ញាណនោះ

ឯង ។ ជួនកាលក៏មានហេតុការណ៍កើតឡើងដែលមានពេញដោយអំណាចចេស្តា គឺនៅពេលដែលយើងថ្វាយបង្គំព្រះនោះឯង ។

## ក. លោកអ័ប្រាហាំនិងលោកយ៉ាកុបនៅឯបេតអែល

នៅក្នុងព្រះគម្ពីរលោកុប្បត្តិជំពូកទី១២ យើងត្រូវបានប្រាប់ថា លោកអ័ប្រាហាំបានសង់អាសនានៅឯបេតអែល ។ ជាច្រើនឆ្នាំកន្លងមកចៅរបស់គាត់ឈ្មោះយ៉ាកុប បានមកដល់បេតអែល ហើយព្រះគម្ពីរបានថ្លែងមកថា គាត់បានដាក់ក្បាលគាត់កើយទៅលើសរសរមួយ ហើយគាត់ក៏បានដេកលក់ទៅ ។ យើងជឿថា សរសរនោះគឺត្រូវបានជាផ្នែកមួយនៃអាសនារបស់លោកអ័ប្រាហាំ ។ គាត់បានយល់សប្តិ តើមានអ្វីកើតឡើងនៅទីនោះ គឺនៅក្នុងតំបន់ខាងឯវិញ្ញាណនោះឯង ។

ព្រះគម្ពីរលោកុប្បត្តិ ២៨:១២-១៣ក

លោកអ៊ីសាកគឺបាននៅកន្លែងរបស់ទេវតា ដែលបានធ្វើសកម្មភាព ។ អរព្រះកុណដល់ព្រះ ដែលទ្រង់បាននៅតែប្រទាននូវការយល់សប្តិ និងការនិម្មិតមកដល់យើងរហូតមកដល់សព្វថ្ងៃនេះ ។ ពួកទេវតាក៏បាននៅទីលើផែនដីក្នុងការ បំពេញការងារដល់ពួកបរិសុទ្ធ ។

ព្រះគម្ពីរហេព្រើរ ១:១៤

## ខ. គំរូរបស់លោកដានីយ៉ែល

នៅក្នុងព្រះគម្ពីរដានីយ៉ែលជំពូកទី១០ ទេវតានាំសារក្នុងការទទួលខុសត្រូវចំពោះពាក្យសម្តី/ការអធិស្ឋានរបស់ហោរាដានីយ៉ែល នោះក៏ត្រូវបានតស៊ូអស់រយៈពេល២១ថ្ងៃ ដោយពួកព្រះអង្គម្ចាស់នៅប្រទេសពើស៊ី ។

សង្គ្រាមខាងឯវិញ្ញាណក៏បានកើតឡើង នៅនគរស្ថានសួគ៌ទៅ ។ ទេវតាក៏ត្រូវបានឃឹតដំណើរដោយពួកអ្នកគ្រប់គ្រងខាងឯវិញ្ញាណងងឹត គឺជានគរពើស៊ី រហូតដល់មហាទេវតាមីកែលបានមកជួយគាត់ ។ នៅក្នុងការទទួលខុសត្រូវនៃពាក្យសម្តីអធិស្ឋានរបស់លោកដានីយ៉ែល នោះអារក្សជាមេនៃសេចក្តីងងឹតក៏បានបើកផ្លូវឱ្យ ហើយទេវតាក៏បានបំបាក់បំបែកការវាំនោះទៅ ។

ព្រះគម្ពីរដានីយ៉ែល ១០:១២-១៣ និងហេព្រើរ ១:១៤

## គ. ការថ្វាយបង្គំអាចបើកទ្វារបាន

ព្រះគម្ពីរលោកុប្បត្តិ ២៨:១៦-១៧

តាមរយៈការថ្វាយបង្គំ នោះនៃស្ថានសួគ៌បានត្រូវបើកឱ្យ។ កន្លែងដែលយើងអង្គុយថ្វាយបង្គំ នោះគឺជាកន្លែងទុក្ខព្រួយ ហើយនគរស្ថានសួគ៌ គឺត្រូវបានបើកឱ្យ ដូចជាព្រះទ្រង់មានបន្ទូលតាមពួកហោរានោះឯង ។ នេះគឺជាទ្វារស្ថានសួគ៌ហើយ ។ យើងអាចបើកនគរស្ថានសួគ៌ ហើយស្តេចនៃសិរីល្អនឹងចុះមកសួរសុខទុក្ខនៅទីនោះ ។

ព្រះគម្ពីរទំនុកដំកើង ២៤:៧

## ឃ. ស្តេចដាវីឌជាអ្នកគង្វាលហ្វូងចៀម

តើវានឹងអាចកើតព្រមគ្នាបានឬទេ ដែលស្តេចដាវីឌកំពុងតែឃ្វាលចៀមផង ហើយក៏ចំណាយពេលជាច្រើនម៉ោងក្នុងការសរសើរដល់ព្រះនៅឯទីវាល ខាងក្រៅក្រុងបេថ្លេហិមនោះ? ឬតើគាត់បានបើកទ្វារស្ថានសួគ៌ នៅពេលដែលគាត់បានថ្វាយបង្គំព្រះនោះ?

វាគឺនៅទីនេះហើយ រាប់រយឆ្នាំក្រោយមក គឺនៅពេលព្រះយេស៊ូវទ្រង់បានប្រសូត នោះពួកទេវតាក៏បានលេចឡើង

មកឯពួកអ្នកគង្វាល ព្រមទាំងបានស្រែកច្រៀង (ព្រះគម្ពីរ លូកា ២:១៤) ។

## III. ការសរសើរគឺអាចបើកផ្ទាំងវាំងននបាន

### ក. វាំងននសេចក្តីងងឹត

លូស៊ីហ្វើរគឺត្រូវបានចាក់ប្រេងតាំងឱ្យធ្វើជាចេរូប៊ីន ដែលធ្វើជាអ្នកគ្របបាំង ។ ធម្មជាតិរបស់វាគឺជាអ្នកគ្របបាំង ។ ប៉ុន្តែ ឥឡូវនេះ ជំនួសឱ្យនូវការគ្របបាំងបល្ល័ង្កនៃព្រះនៅនគរស្ថានសួគ៌ជាមួយនឹងការសរសើរ និងថ្វាយបង្គំពេញដោយសិរីល្អ នោះវាត្រូវបានមកគ្របបាំងលើផែនដីធ្វើជាម្ចាស់នៃសេចក្តីងងឹតវិញ ។

ព្រះគម្ពីរអេសាយ ៦០:២

សាតាំងបានត្រូវកំណត់ឱ្យធ្វើជាម្ចាស់គ្រប់គ្រង មកលើសេចក្តីងងឹត លើអាណាខេត្តដើម្បីការពារនូវការបំបែកបំបាក់របស់ព្រះតាមរយៈមនុស្សជាតិ ។

ព្រះគម្ពីរអេភេសូរ ៦:១២

គោលបំណងរបស់វាំងននៃសេចក្តីងងឹត គឺត្រូវតែធ្វើឱ្យ មនុស្សជាតទាំងអស់ទៅជាខ្វាក់ ដើម្បីពង្វក់ពួកគេឱ្យចេញពីការទទួលនូវសិរីល្អរបស់ព្រះ ។

ព្រះគម្ពីរ ២កូរិនថូស

### ខ. សង្គ្រាមដ៏មានពេញដោយអំណាចចេស្តា

វត្ថុដែលមានពេញដោយអំណាចចេស្តា ដែលបានកើតឡើង គឺនៅពេលដែលយើងស្អាងអាសនានៃការសរសើរ និងការថ្វាយបង្គំ ។ "ផ្ទៃនៃការគ្របបាំង" របស់វាំងនននៃសេចក្តីងងឹតខាងវិញ្ញាណគឺត្រូវបានកាត់ផ្តាច់ និងត្រូវបានបំផ្លាញ ។ អ្នកគ្រប់គ្រងលើសេចក្តីងងឹត គឺលើអាណាខេត្តនោះត្រូវបានចុះចាញ់ហើយ ។

ព្រះគម្ពីរអេសាយ ២៥:៧

នៅពេលដែលយើងបើកនគរស្ថានសួគ៌ តាមរយៈការសរសើរ និងការថ្វាយបង្គំៈ ពួកទេវតាអាចលេចឡើង ព្រះអង្គទ្រង់ក៏បានយាងមក រីឯព្រះវត្តមានព្រះអង្គក៏ត្រូវបានគង់នៅជាមួយដែរ ។

## IV. ជ័យជម្នះតាមរយៈការសរសើរ

### ក. ជ័យជម្នះរបស់ស្តេចយ៉ូសាផាត

ជ័យជម្នះរបស់ស្តេចយ៉ូសាផាត គឺជាគំរូមួយដ៏ធំបំផុតនៃជ័យជម្នះតាមរយៈការសរសើរ និងការថ្វាយបង្គំ ។

នៅភេលដែលពួកយូដាត្រូវបានទទួលការឈ្លានពានពីពួកកងទ័ពទាំងបីជនជាតិ (អាំម៉ូន ម៉ូអាប់ និងអ្នកភ្នំសេីរ) នោះពួកគេបានរកឃើញដោយខ្លួនឯង នូវក្តីអស់សង្ឃឹមដ៏លើសលុប ប៉ន្តែ ស្តេចយ៉ូសាផាត និងពួកសាសន៍យូដាបានដឹងពីអ្វីដែលត្រូវធ្វើ ។ ពួកគេបានស្រែកទៅរកព្រះយេហូវ៉ា ។

ព្រះគម្ពីរ ២របាក្សត្រ ២០:១៥

ឥឡូវនេះ លោកអ្នកក៏អាចត្រូវបានចូលរួម ក្នុងស្ថានការណ៏អស់សង្ឃឹមនោះដែរ ។ យើងមានសេចក្តីសង្ឃឹម ។ លោកអ្នកក៏ត្រូវការការអស្ចារ្យរបៀបនោះដែរ ។ ការថ្វាយបង្គំដល់ព្រះអម្ចាស់ និងការនិងការស្វែងរកព្រះភក្រ្តទ្រង់នោះនឹងគ្មានការភ័យខ្លាច នៅទីសមរភូមិគឺមិនមែនជារបស់លោកអ្នកទេ គឺជារបស់ព្រះអម្ចាស់វិញ ។

#### ១. តួនាទីរបស់លោកអ្នកផ្ទាល់

ព្រះគម្ពីរ ២របាក្សត្រ ២០:១៧ក,១៨

ព្រះបន្ទូលរបស់ព្រះយេហូវ៉ា បានមកដល់ពួកគេ "តួនាទីរបស់ពួកគេផ្ទាល់" ហើយពួកគេក៏ធ្វើការនោះតាមរយៈការថ្វាយបង្គំ! ពួកគេបានចាប់ផ្ដើមសរសើរដល់ព្រះយេហូវ៉ា ដោយមានការស្ដាប់បង្គាប់ គឺនៅពេលដែលពួកគេបានប្រឈមមុខ នឹងភាពអស់សង្ឃឹមខាងផ្នែកធម្មជាតិរបស់គេ ។ ពួកគេបានសរសើរនៅមុនពេលបានទទួលនូវជ័យជម្នះ គឺមិនមែនបន្ទាប់ពីបានទទួលនូវជ័យជម្នះនោះទេ ។

ព្រះគម្ពីរ ២របាក្សត្រ ២០:១៩

**២. ការដាក់ពួកអ្នកសរសើរឱ្យនៅពីមុខ**

ព្រះគម្ពីរ ២របាក្សត្រ ២០:២១-២២

**៣. ពួកខ្មាំងសត្រូវត្រូវបានបំផ្លាញគ្នាទៅវិញទៅមក**

ព្រះគម្ពីរ ២របាក្សត្រ ២០:២៣-២៤

សូម្បីតែនៅពេល ដែលវាបានកើតមកយ៉ាងដូច្នោះក៏ដោយ ក៏ពួកខ្មាំងសត្រូវរបស់យើង ដែលមានគ្នាដ៏ច្រើនលើសលុប នោះមានការចុះចូលជាមួយយើងផងដែរ គឺប្រសិនបើយើងដាក់តួនាទីរបស់យើង ទៅឱ្យព្រះអម្ចាស់វិញ គឺយើងចាប់សរសើរ និងថ្វាយបង្គំដល់ទ្រង់ នោះតំបន់ខាងឯវិញ្ញាណនឹងត្រូវចូលមកឯយើងជាក់ជាមិនខាន ។

**៤. ការធ្វើសង្គ្រាមតាមរយៈការសរសើរ**

សាតាំងនិងអ្នកដើរតាមវា ដែលពីដើមក៏ធ្លាប់បានជាអ្នកសរសើរ នៅឯនគរស្ថានសួគ៌នោះដែរ ។ ពួកវាមិនអាចឈរនៅក្នុងសម្លេងសរសើរ នោះបានឡើយ ។ ពួកទេវតាជាអ្នកបញ្ជូនសារ ដែលបានទទួលការប្រើមកពីព្រះយេហូវ៉ា នោះនឹងពួនស្ទាក់ចាំចាប់ពួកកងកម្លាំងវិញ្ញាណអាក្រក់ទាំងនោះ ។ ដោយការភាន់ច្រឡំនោះ ពួកគេបានវិលបែរទៅវាយគ្នាទៅវិញទៅមក រហូតទទួលនូវការបរាជ័យ គឺនៅពេលដែលយើង បានចាប់ផ្ដើមសរសើរដល់ព្រះយេហូវ៉ា ។

មានមនុស្សជាច្រើន គឺនៅពេលដែលពួកគេបានសិក្សា នោះយើងក៏នៅឯទីសង្គ្រាមជាមួយនឹងខ្មាំងសត្រូវ ក៏បានចំណាយពេលជាច្រើន រហូតដល់ទៅជាស្គមស្គាំងនៅជាមួយនឹងអារក្ស ព្រមទាំងពពួកវិញ្ញាណអាក្រក់របស់វា ។ ពួកគេបានផ្ចង់ចិត្តទៅឯខ្មាំងសត្រូវនោះ ។ មានកន្លែងមួយសម្រាប់ការប្រគំបទភ្លេង ដែលមានសង្គ្រាមនៅសម័យសព្វថ្ងៃនេះ ។ វាគួរតែបានរំឭកយើង ពីសិទ្ធិអំណាចដ៏មានជ័យជម្នះរបស់យើង ទៅលើខ្មាំងសត្រូវ និងរំឭកដល់សាតាំងដែលវាបានទទួលនូវការបរាជ័យហើយនោះវិញ!

ទោះជាយ៉ាងណាក៏ដោយ សង្គ្រាមដែលបានទទួលនូវជ័យជម្នះនៅក្នុងការសរសើរ គឺមិនមែនជាការតូចស្ដើង ចំពោះខ្មាំងសត្រូវនោះទេ ។ វាគឺជាការសរសើរ ដែលបានដាក់ជាកណ្ដាលនៃភាពដ៏ធំឧត្ដម របស់ព្រះនៃយើងប៉ុណ្ណោះ ។

ព្រះគម្ពីរទំនុកដំកើង ១៤៩:៦-៩

ព្រះគម្ពីរអេសាយ ៣០:៣២

ឧបករណ៏នៃការសរសើរ និងការថ្វាយបង្គំ នោះនឹងមានន័យទៅលើជ័យជម្នះលើខ្មាំងសត្រូវ ។ ជ័យជម្នះ គឺបានមកដល់យើងហើយ ។

## ៩. ជ័យជម្នះរបស់ស្តេចយ៉ូសាផាត

ពួកអ្នកសរសើរគឺនៅពីខាងមុខ ពួកកងទ័ពរបស់ស្តេចយ៉ូសាផាត គឺមិនមែនច្រៀងចម្រៀងធ្វើសង្គ្រាម តម្រង់សំដៅទៅលើវិញ្ញាណអាក្រក់នោះទេ ។ ពួកគេបានកំពុងតែច្រៀង "សរសើរពីភាពស្រស់ស្អាតលើភាពបរិសុទ្ធ ។ សរសើរដល់ព្រះយេហូវ៉ា សម្រាប់សេចក្តីមេត្តាករុណា សេចក្តីទ្រាំទ្ររបស់ទ្រង់ដ៏នៅអស់កល្បជានិច្ច" ។ គឺពួកគេកំពុងតែបានថ្វាយបង្គំដល់ព្រះ!

## ខ. លោកសាវ័កប៉ុល និងស៊ីឡាស

នៅទីក្រុងភីលីព លោកប៉ុលនិងលោកស៊ីឡាស ត្រូវបានគេវាយឱ្យរបួស ទទួលភាពល្វីងជូរចត់ និងបោះចូលទៅក្នុងគុក ជាមួយនឹងជើងត្រូវជាប់ខ្នោះទៀតផង ។ ទ្វារគុកសុទ្ធតែចាក់សោរទាំងអស់ និងមានអ្នកយាមល្បាតនៅការពារថែមទៀត ។ តើពួកគេនឹងត្រូវបាន ចោលនឹងដុំសម្លាប់ឬ? ប៉ុន្តែលោកប៉ុល និងលោកស៊ីឡាសបានអធិស្ឋាន និងច្រៀងទំនុកតម្កើងថ្វាយដល់ព្រះ ។ តើអ្នកជាប់គុកដទៃទៀតយ៉ាងណាដែរ តើបានគិតថានឹងស្តាប់ចម្រៀង នៅក្នុងកាលៈទេសៈរបៀបនេះឬ? មានការបំបែកបំបាក់ ហើយរាំងននៃសេចក្តីងងឹតក៏ត្រូវបានបើកឡើងហើយ ។ ភ្នែកអ្នកទោសទាំងឡាយក៏បានបើក ក៏នឹងចង់បានទទួលព្រះយេស៊ូវផងដែរ ។

ព្រះគម្ពីរកិច្ចការ ១៦:២៥-២៦

## គ. ការអធិស្ឋានតម

នៅក្នុងពេលវេលាដ៏ងងឹតបំផុតនោះ យើងត្រូវតែបន្តថ្វាយនូវដង្វាយយញ្ញបូជានៃការសរសើរ មិនមែនជាបញ្ហាណាមួយដែលមិនអាចធ្វើបាននោះទេ គឺស្ថានការណ៍ដែលត្រូវលេចឡើង ។ នៅពេលដែលយើងធ្វើយ៉ាងដូច្នេះ នោះគឺតែងតែមានលទ្ធផល ដែលមានពេញដោយអំណាចចេស្តា ។ ជ័យជម្នះអាចចូលមកតាមរយៈការសរសើរដ៏ខ្ពស់ និងការថ្វាយបង្គំដ៏ស្និទ្ធស្នាល ។ ពួកទេវតានឹងបញ្ចេញសកម្មភាព ។ ព្រះទ្រង់នឹងមានព្រះបន្ទូល ។

យើងក៏អាចឯកភាពជាមួយនឹងស្តេចដាវីឌ នៅពេលដែលទ្រង់បានសរសេរចារទុកមកនេះ ។

ព្រះគម្ពីរទំនុកដំកើង ៦៨:១ក

យើងនឹងចូលរួមជាមួយនឹងយ៉ាកុប ហើយនិយាយៈ ព្រះគម្ពីរលោកុប្បត្តិ ២៨:១៦-១៧ ។

## ក្រុមពិភាក្សា

១. ហេតុអ្វីបានជាយើងសរសើរព្រះ ដោយអស់ពីចិត្ត អស់ពីព្រលឹង និងអស់ពីរូបកាយ ប៉ុន្តែ យើងអាចត្រឹមតែថ្វាយបង្គំទ្រង់ដោយវិញ្ញាណឬ?

២. តើការថ្វាយបង្គំព្រះដោយវិញ្ញាណ និងសេចក្តីពិតដោយរបៀបណា ក្នុងការសាងសង់អាសនាខាងឯវិញ្ញាណ?

៣. ហេតុអ្វីបានជាវាមិនមែនជាជំនួយ ឱ្យវិញ្ញាណអាក្រក់ដែលស្គមស្គាំងកំឡុងសង្គ្រាមខាងឯវិញ្ញាណនោះ?

## ការសិក្សាដោយខ្លួនឯង

១. តើលោកអ្នកអាចរៀនសូត្រពីការលង់ចូល ទៅក្នុងព្រះវត្តមានរបស់ទ្រង់ និងសរសើរព្រះអង្គ រហូតដល់សិរីល្អបានធ្លាក់ចុះមកឬ?

២. នៅពេលណា និងរបៀបណា ដែលចិត្តរបស់យើងបានត្រឡប់មកជាដីឥដ្ឋដ៏ទន់វិញ នៅក្នុងព្រះហស្តរបស់ព្រះនោះ?

៣. ហេតុអ្វី បានជាយើងនៅតែបន្តថ្វាយដង្វាយយញ្ញបូជានៃការសរសើរ និងការថ្វាយបង្គំដ៏ជិតស្និទ្ធ?